សំរាប់ការថែទាំមួយចំនួន PCD ឬទន្តបណ្ឌិតរបស់អ្នកនឹងត្រូវសួរយើងជាមុន មុនពេលអ្នកទទួលការថែទាំ។ នេះត្រូវបានហៅថាការអនុញ្ញាតផ្តល់សិទ្ធិទុកជាមុនឬការឯកភាពជាមុន។ វាមានន័យថាគម្រោង LIBERTY បានយល់ស្របថាការថែទាំមានលក្ខណៈចាំបាច់ផ្នែកវេជ្ជសាស្ត្រមែន។

ការថែទាំគឺជាការចាំបាច់ខាងវេជ្ជសាស្ត្រប្រសិនបើវាមានគោលបំណងដើម្បីបង្ការនិងលុបបំបាត់ជំងឺមាត់ធ្មេញ ការឆ្លងមេរោគនិងការឈឺចាប់ដើម្បីស្តារទម្រង់និងមុខងារធ្មេញឡើងវិញឬដើម្បីកែតម្រូវភាពមិនប្រក្រតីឬកំហូចមុខងារធ្មេញ។ សេវាកម្មទន្តសាស្ត្រត្រូវតែបំពេញបានគ្រប់ទៅនឹងក្រិតក្រមច្បាប់នៃកម្មវិធី Medi-Cal សម្រាប់ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

សេវាកម្មធ្មេញទាំងនេះត្រូវមានការយល់ព្រមជាមុនបើទោះបីជាអ្នកបានទទួលវាពីអ្នកផ្តល់សេវាកម្មក្នុងបណ្តាញ LIBERTY ក៏ដោយ:

- ការព្យាបាលការពុកនៅប្រហោងឬសធ្មេញ
- តួធ្មេញសិប្ប៖និម្មិត
- ធ្មេញសិប្ប៖និម្មិតពេញក្រាស់
- ការចាក់ពុម្ពរាងវៅធ្មេញសិប្ប៖និម្មិតឡើងវិញ
- ការសម្អាតជ្រៅ (ការឆ្លុះសម្អាតនិងការសម្អាតគល់ធ្មេញ)
- សេវាកម្មទន្តសាស្ត្រទូទៅនិងការចាក់ថ្នាំឱ្យស្លប់អារម្មណ៍តាមសរសៃវ៉ែន

សេវាកម្មទន្តសាស្ត្រដទៃទៀតដែលទន្តបណ្ឌិតអ្នកណែនាំជាអនុសាសន៍ក៏អាចនឹងទាមទារតម្រូវឱ្យមានទូវការឯកភាពជាមុនផងដែរ។

សំរាប់សេវាកម្មមួយចំនួនដូចជាការថែទាំពីទន្តបណ្ឌិតឯកទេស អ្នកត្រូវការការយល់ព្រមជាមុនប្រសិនបើអ្នកទទួលបានការថែទាំពីក្រៅបណ្តាញ។ យើងខ្ញុំនឹងសម្រេចចិត្តក្នុងរង្វង់ 5 ថ្ងៃធ្វើការ សម្រាប់សេវាកម្មជាប្រចាំ ឬ 72 ម៉ោងសម្រាប់ការថែទាំបន្ទាន់។

យើងពិនិត្យឡើងវិញនូវសំណើរសុំដើម្បីសំរេចថាតើការថែទាំនេះមានសារៈសំខាន់ខាងវេជ្ជសាស្ត្រនិងត្រូវទទួលបានការគ្រប់ដណ្ដប់ឬទេ។ យើង **មិន** បង់ថ្លៃអ្នកត្រួតពិនិត្យសើរើឡើងវិញរបស់យើងខ្ញុំដើម្បីបដិសេធការធានារ៉ាប់រងឬសេវាកម្មទន្តសាស្ត្រនោះឡើយ។ ប្រសិនបើយើងខ្ញុំមិនឯកភាពយល់ព្រមលើការថែទាំទេនោះ យើងខ្ញុំនឹងប្រាប់អ្នកថាហេតុអ្វី។

LIBERTY នឹងទាក់ទងទៅកាន់អ្នកប្រសិនបើយើងត្រូវការព័ត៌មានបន្ថែមទៀតឬពេលវេលាបន្ថែមទៀតដើម្បីត្រួតពិនិត្យសើរើសំណើ

របស់អ្នក។

គំនិតយោបល់ទីពីរ

អ្នកអាចនឹងចង់បានគំនិតយោបល់ទីពីរអំពីការថែទាំដែល PCD របស់អ្នកនិយាយថាអ្នកត្រូវការឬអំពីរោគវិនិច្ឆ័យឬគម្រោងព្យាបាលរបស់អ្នក។ ឧទាហរណ៍ អ្នកអាចនឹងចង់បានគំនិតយោបល់ទីពីរប្រសិនបើអ្នកមិនច្បាស់ប្រាកដថាអ្នកត្រូវការការព្យាបាលឬការរះកាត់តាមការចេញវេជ្ជបញ្ជាឬទេនោះ។

ដើម្បីបានគំនិតយោបល់ទីពីរ សូមហៅទូរស័ព្ទទៅកាន់ PCD របស់អ្នក។ PCD របស់អ្នកអាចបញ្ជូនអ្នកបន្តទៅកាន់អ្នកផ្តល់សេវាកម្មក្នុងបណ្តាញសម្រាប់យោបល់ទីពីរ។ ឬហៅទៅកាន់លេខ 888-703-6999 (TTY 800-735-2929)។

យើងនឹងចំណាយថ្លៃសម្រាប់ការស្វែងរកគំនិតទី 2 ប្រសិនបើអ្នកឬទន្តបណ្ឌិតក្នុងបណ្តាញរបស់អ្នកស្នើរសុំវា ហើយអ្នកទទួលបានយោបល់ទីពីរពីទន្តបណ្ឌិតក្នុងបណ្តាញ។ អ្នកមិនត្រូវការការអនុញ្ញាតិពីយើងដើម្បីទទួលបានយោបល់ទីពីរនោះទេប្រសិនបើទន្តបណ្ឌិតដែលអ្នកជ្រើសរើសយកដើម្បីសុំយោបល់ទីពីរត្រូវបានអនុម័តជាជាមុន។ ប្រសិនបើអ្នកមានសំណួមពរជាបន្ទាន់ យើងនឹងធ្វើការសំរេចចិត្តក្នុងរយៈពេល 72 ម៉ោង។

សូមទូរស័ព្ទទៅផ្នែកសេវាកម្មសមាជិកតាមរយៈលេខ 888-703-6999 (TTY 800-735-2929)។

ប្រសិនបើយើងខ្ញុំបដិសេធសំណើសុំរបស់អ្នកសម្រាប់គំនិតយោបល់ទីពីរ អ្នកអាចនឹងប្តឹងឧទ្ធរណ៍បាន។ ដើម្បីស្វែងយល់បន្ថែមអំពីបណ្តឹងឧទ្ធរណ៍ សូមទៅកាន់ ទំព័រ 45 នៅក្នុងកូនសៀវភៅនេះ។

ការមានលទ្ធភាពទទួលបានការថែទាំទាន់ពេលវេលា

LIBERTY ត្រូវផ្តល់ការណាត់ជួបក្នុងកំឡុងពេលដូចខាងក្រោម៖

- ការណាត់ជួបធម្មតា (រួមបញ្ចូលទាំងការថែទាំការពារ) - 4 សប្តាហ៍
- ការណាត់ជួបអ្នកជំនាញ - 30 ថ្ងៃនៃថ្ងៃធ្វើការ (អាយុ 21 ឡើងទៅ) ។ 30 ថ្ងៃនៃថ្ងៃប្រតិទិន (ក្រោមអាយុ 21 ឆ្នាំ)
- ការណាត់ជួបថែទាំបន្ទាន់ - 72 ម៉ោង
- ការថែទាំករណីអាសន្ន - ត្រូវមាន 24 ម៉ោង និងរកបាន 7 ថ្ងៃក្នុងមួយសប្តាហ៍

4. អត្ថប្រយោជន៍និងសេវាកម្មផ្សេងៗ

អ្វីដែលគម្រោងធានារ៉ាប់រងទន្តសាស្ត្ររបស់អ្នកធានារ៉ាប់រង

ក្នុងផ្នែកនេះយើងពន្យល់ពីសេវាកម្មដែលត្រូវបានរ៉ាប់រងទាំងអស់សម្រាប់សមាជិករបស់ LIBERTY ។ សេវាកម្មដែលមានការគ្របដណ្តប់របស់អ្នកមិនគិតថ្លៃចំពោះអ្នកទេ ដរាបណាពួកគេមានភាពចាំបាច់ខាងវេជ្ជសាស្ត្រ។ ការថែទាំគឺជាការចាំបាច់ខាងវេជ្ជសាស្ត្រប្រសិនបើវាមានគោលបំណងដើម្បីបង្ការនិងលុបបំបាត់ជំងឺមាត់ធ្មេញ ការឆ្លងមេរោគនិងការឈឺចាប់ដើម្បីស្តារទម្រង់និងមុខងារធ្មេញឡើងវិញ ហើយដើម្បីកែតម្រូវការខុសទ្រង់ទ្រាយនិងមុខងារមិនប្រក្រតីនៃមុន។

យើងផ្តល់នូវប្រភេទទាំងនេះនៃសេវាកម្មទន្តសាស្ត្រ:

ប្រភេទសេវាកម្ម	ឧទាហរណ៍
• នៃការធ្វើរោគវិនិច្ឆ័យ	ការពិនិត្យនិងការថតកាំរស្មីអ៊ិច
• ដែលមានលក្ខណៈបង្ការជាមុន	ការសម្អាត ការព្យាបាលដោយជាតិហ្លួយអ‍ីរ ការប៉ះបិទភ្ជិត
• ការស្តារត្រលប់ឱ្យដូចដើមវិញ	ការប៉ះបំពេញប្រហោងធ្មេញការបន្ពប្ចតួធ្មេញសិប្បនិម្មិត
• ទន្តសាស្ត្រឯកទេសបណ្តូលក្នុងធ្មេញ	ការសម្អាតយកចេញបណ្តូលធ្មេញ ការព្យាបាលការពុកនៅប្រហោងឫសធ្មេញ
• ទន្តសាស្ត្រទាក់ទងរចនាសម្ព័ន្ធជុំវិញធ្មេញ	ការវះកាត់អញ្ចាញ
• សរីរាង្គសិប្បនិម្មិតនៃធ្មេញដែលអាចដោះចេញបាន	ធ្មេញសិប្បនិម្មិតពេញក្រាស់ដាក់ភ្លាមក្រោយដកធ្មេញធម្មជាតិចាក់ពុម្ពរាងរៅឡើងវិញ
• ការវះកាត់មាត់និងថ្គាម-មុខ	ការដកធ្មេញ
• ការតម្រង់អញ្ចាញ	ខ្សែរឹតតម្រង់ធ្មេញ
• ជម្ងឺដរពីធ្មេញ	ការដាក់ថ្នាំឱ្យស្រូប ការដាក់ថ្នាំសណ្តាំទូទៅ

អានសេចក្តីសង្ខេបនៃអត្ថប្រយោជន៍និងផ្នែកនីមួយៗខាងក្រោមនេះដើម្បីស្វែងយល់បន្ថែមអំពីសេវាកម្មជាក់លាក់ដែលអ្នកអាចទទួលបាន។

សេចក្តីសង្ខេបនៃអត្ថប្រយោជន៍

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃអត្ថប្រយោជន៍ធ្មេញសម្រាប់មនុស្សពេញវ័យនិងកុមារ៖

✓ អត្ថប្រយោជន៍ ✗ មិនមែនជាអត្ថប្រយោជន៍

ទម្រង់ការ	វិសាលភាពពេញលេញ	វិសាលភាពដែលត្រូវបានដាក់កម្រិត	ពាក់ព័ន្ធនឹងការមានផ្ទៃពោះ	ការរស់នៅក្នុងមណ្ឌលព្យាបាល (SNF/ICF)
ការវាយតម្លៃមាត់ធ្មេញ (ក្រោមអាយុ 3 ឆ្នាំ)	✓	✗	✗	✓
ការពិនិត្យលើកដំបូង (អាយុ 3 ឆ្នាំឡើង)	✓	✗	✓	✓
ការពិនិត្យម្តងម្តាល (អាយុ 3 ឆ្នាំឡើង)	✓	✗	✓	✓
ការសំអាតធម្មតា	✓	✗	✓	✓
សារធាតុហ្លួយអ៊ីរ	✓	✗	✓	✓
សេវាស្តារឡើងវិញ - ការបំពេញ/ការស្រោប	✓	✗	✓	✓
ការស្រោបធ្មេញ*	✓	✗	✓	✓
ការធ្វើតម្រឹមនិងការរៀបចំឬស (សំអាតជ្រៅ)**	✓	✗	✓	✓
ការថែទាំរចនាសម្ព័ន្ធជុំវិញធ្មេញ (អញ្ចាញ)	✗	✗	✗	✓
ការព្យាបាលការពុកនៅប្រហោងឬសធ្មេញខាងមុខ (ធ្មេញមុខ)	✓	✗	✓	✓
ការព្យាបាលការពុកនៅប្រហោងឬសធ្មេញខាងក្រោយ (ធ្មេញក្រោយ)	✓	✗	✓	✓
ធ្មេញសិប្បនិម្មិតមិនពេញក្រាស់	✓	✗	✓	✓
ធ្មេញសិប្បនិម្មិតពេញក្រាស់	✓	✗	✓	✓
ការដកធ្មេញ/ការរះកាត់មាត់និងថ្គាមមុខ	✓	✓	✓	✓
សេវាកម្មសង្គ្រោះបន្ទាន់	✓	✓	✓	✓

ការលើកលែង:

*1. មិនមែនជាអត្ថប្រយោជន៍សម្រាប់អ្នកក្រោមអាយុ 13 ឆ្នាំ
2. អាយុលើសពី 21 ឆ្នាំនឹងទទួលបានអនុញ្ញាតក្នុងកាល:ទេស:ពិសេសសម្រាប់ធ្មេញក្រោយ។

**មិនមែនជាអត្ថប្រយោជន៍នៅក្រោមអាយុ 13 ឆ្នាំ។ អនុញ្ញាតបាននៅក្រោមកាល:ទេស:ពិសេស។

ភាពញឹកញាប់នៃសេវា

សេវាកម្មសុខភាពធ្មេញត្រូវបានគ្របដណ្តប់ប្រសិនបើចាំបាច់ខាងវេជ្ជសាស្ត្រ។ ទោះយ៉ាងណាក៏ដោយសម្រាប់សេវាកម្មមួយចំនួន ពួកគេមានដែនកំនត់ថាតើអ្នកអាចទទួលបានសេវាកម្មប៉ុន្មានដងក្នុងរយៈពេលមួយជាក់លាក់។ ខាងក្រោមគឺជាសេវាកម្មទូទៅដែលមានដែនកំណត់៖

- ការពិនិត្យ - រៀងរាល់ 6 ខែ (អាយុក្រោម 21 ឆ្នាំ) រៀងរាល់ 12 ខែ (អាយុ 21 ឆ្នាំឡើង)
- ការថតកាំរស្មីអ៊ិចធ្មេញផ្តាមសងខាងដោយធ្មេញបង្ហាំគ្នា--រៀងរាល់ 6 ខែ
- ការថតកាំរស្មីអ៊ិចពេញមាត់--រៀងរាល់ 36 ខែ
- ការថតកាំរស្មីអ៊ិចជុំវិញមើលម្តងពេញមាត់ទាំងអស់ - រៀងរាល់ 36 ខែ
- ការសំអាតធ្មេញ - រៀងរាល់ 6 ខែ (ក្រោមអាយុ 21 ឆ្នាំ) រៀងរាល់ 12 ខែ (អាយុ 21 ឆ្នាំឡើង)
- ការដុះសម្អាតដោយជាតិភ្លួយអរ - រៀងរាល់ 6 ខែ (ក្រោមអាយុ 21 ឆ្នាំ) រៀងរាល់ 12 ខែ (អាយុ 21 ឆ្នាំឡើង)
- ការព្យាបាលការពារធ្មេញពុក - រៀងរាល់ 36 ខែ (អាយុក្រោម 21 ឆ្នាំប៉ុណ្ណោះ)
- ការបំពេញចន្លោះធ្មេញ - រៀងរាល់ 12 ខែ (ក្នុងមួយធ្មេញថ្មី) រៀងរាល់ 36 ខែ (ក្នុងមួយធ្មេញអចិន្ត្រៃយ៍)
- ស្រោបធ្មេញ - រៀងរាល់ 5 ឆ្នាំ (អាយុ 13 ឆ្នាំឡើង)
- ការលាងសំអាតជ្រៅ (ការតម្រឹម/ការដាំគល់ធ្មេញ) - រៀងរាល់ 24 ខែក្នុងក្រាសធ្មេញមួយចំហៀង (អាយុ 13 ឆ្នាំឡើង)
- ធ្មេញពាក់ពេញនិងតាមផ្នែក - រៀងរាល់ 5 ឆ្នាំម្តង
- ការជួសជុលនិងថែទាំធ្មេញ - ពីរដងក្នុងមួយឆ្នាំ

សេវាថែទាំធ្មេញបន្ថែមសម្រាប់កុមារ

សេវាកម្មពិនិត្យរាវរកជំងឺ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលលឿនពីដើមទីនិងយូរៗម្តងម្តាល (EPSDT)

យើងធានារ៉ាប់រងលើសេវាកម្ម EPSDT។ សេវាកម្ម EPSDT រួមមានសេវាកម្មទាំងអស់ដែលគ្របដណ្តប់ដោយ Denti-Cal ។ ប្រសិនបើអ្នកមានអាយុក្រោម 21 ឆ្នាំ អ្នកអាចទទួលបាននូវសេវាកម្មបន្ថែមដែលមិនត្រូវបានរ៉ាប់រងដោយ Denti-Cal ដរាបណាពួកគេមានភាពចាំបាច់ខាងវេជ្ជសាស្ត្រ។ សេវាកម្មទាំងនេះនឹងត្រូវបន្ថែមទៅនឹងអត្ថប្រយោជន៍ Denti-Cal ធម្មតា។

ប្រសិនបើអ្នកត្រូវការសេវាកម្មណាមួយក្នុងចំណោមសេវាកម្មទាំងនេះ ពេទ្យធ្មេញរបស់អ្នកនឹងសួរយើង។ សំណើទាំងអស់ត្រូវផ្ញើទៅ LIBERTY សម្រាប់ការអនុម័ត។

ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែមអំពីអត្ថប្រយោជន៍របស់ EPSDT សូមហៅទៅលេខ 888-703-6999 (TTY 800-735-2929) ។

ការដឹកជញ្ជូនវេជ្ជសាស្ត្រមិនមែនការណីសង្គ្រោះបន្ទាន់

អ្នកមានសិទ្ធិសាកសមនឹងទទួលបានការប្រើប្រាស់នូវការដឹកជញ្ជូនវេជ្ជសាស្ត្រមិនមែនការណីសង្គ្រោះបន្ទាន់ (NEMT) នៅពេលអ្នកមិនអាចទាំងផ្នែកផ្លូវកាយឬផ្លូវវេជ្ជសាស្ត្រទៅកាន់ការណាត់ជួបវេជ្ជសាស្ត្ររបស់អ្នកដោយរថយន្ត រថយន្តក្រុង រថភ្លើងឬតាក់ស៊ីហើយគម្រោងបង់ថ្លៃជូនសម្រាប់សភាពជំងឺទន្តសាស្ត្ររបស់អ្នក។

NEMT គឺជាការដឹកជញ្ជូនដោយរថយន្តគិលានសង្គ្រោះ រថយន្តវែងទេសចរណ៍បំពាក់ដោយគ្រែស្នែងអ្នកជំងឺ រថយន្តវែងទេសចរណ៍ដែលមានកៅអីរុញ ឬការដឹកជញ្ជូនតាមផ្លូវអាកាស។ NEMT មិនមែនជារថយន្ត រថយន្តក្រុង ឬរថយន្តតាក់ស៊ីនោះឡើយ។ LIBERTY អនុញ្ញាតជូននូវ NEMT ដែលមានតម្លៃទាបបំផុតសម្រាប់តម្រូវការវេជ្ជសាស្ត្ររបស់អ្នកនៅពេលអ្នកត្រូវការការជិះទៅកាន់ការណាត់ជួបរបស់អ្នក។ នោះមានន័យថា ជាឧទាហរណ៍ ប្រសិនបើអ្នកអាចតាមផ្លូវកាយឬផ្លូវវេជ្ជសាស្ត្រត្រូវបានគេដឹកជញ្ជូនដោយរថយន្តវែងប្រភេទទេសចរណ៍ដែលមានបំពាក់ដោយកៅអីរុញ នោះគម្រោង LIBERTY នឹងមិនបង់ថ្លៃជូនសម្រាប់រថយន្តគិលានសង្គ្រោះនោះឡើយ។ អ្នកមានសិទ្ធិសាកសមទទួលបានការដឹកជញ្ជូនតាមផ្លូវអាកាសតែប្រសិនបើស្ថានភាពវេជ្ជសាស្ត្ររបស់អ្នកធ្វើឱ្យទម្រង់ណាមួយក៏ដោយនៃការដឹកជញ្ជូនតាមផ្លូវគោកមិនអាចទៅរួច។

NEMT ត្រូវតែប្រើប្រាស់នៅពេលដែលវា:

- ត្រូវការជាលក្ខណៈផ្លូវកាយឬផ្លូវវេជ្ជសាស្ត្រដូចដែលបានកំណត់ដោយវេជ្ជបណ្ឌិតជាលាយលក្ខណ៍អក្សរដោយគ្រូពេទ្យ
- អ្នកមិនអាចប្រើប្រាស់រថយន្តក្រុង រថយន្តតាក់ស៊ី រថយន្ត ឬរថយន្តវែងប្រភេទទេសចរណ៍តាមផ្លូវកាយ ឬជាលក្ខណៈវេជ្ជសាស្ត្របានដើម្បីទៅកាន់ការណាត់ជួបរបស់អ្នក។
- ត្រូវបានឯកភាពយល់ព្រមជាមុនដោយគម្រោង LIBERTY ដោយវេជ្ជបណ្ឌិតជាលាយលក្ខណ៍អក្សរដោយគ្រូពេទ្យ។

ដើម្បីស្នើរសុំ NEMT សូមទូរស័ព្ទទៅ LIBERTY តាមលេខ 877-550-3868 យ៉ាងហោចណាស់ 10 ថ្ងៃធ្វើការ (ច័ន្ទ - ថ្ងៃសុក្រ) មុនពេលការណាត់ជួបរបស់អ្នក។ សម្រាប់ការណាត់ជួបករណីបន្ទាន់ សូមហៅទូរស័ព្ទឱ្យបានលឿនតាមដែលអាចធ្វើបាន។ សូមត្រៀមប័ណ្ណសម្គាល់សមាជិករបស់អ្នកឱ្យបានរួចរាល់នៅពេលអ្នកហៅទូរស័ព្ទ។

កម្រិតកំណត់នៃ NEMT

មិនមានកម្រិតកំណត់សម្រាប់ការទទួលបាននូវ NEMT ទៅកាន់ឬមកពីការណាត់ជួបទន្តសាស្ត្រដែលត្រូវបានធានារ៉ាប់រងនៅក្រោមគម្រោង LIBERTY ឡើយនៅពេលដែលអ្នកផ្តល់សេវាកម្មបានចេញវេជ្ជបញ្ជាវាសម្រាប់អ្នក។

តើអ្វីដែលមិនអាចអនុវត្តន៍បាន?

ប្រសិនបើស្ថានភាពរាងកាយនិងវេជ្ជសាស្ត្ររបស់អ្នកអនុញ្ញាតឱ្យអ្នកទៅកាន់កន្លែងណាត់ជួបវេជ្ជសាស្ត្រដោយរថយន្តឡានក្រុង តាក់ស៊ីឬមធ្យោបាយដឹកជញ្ជូនដោយស្រួលផ្សេងទៀតបាន។ ការដឹកជញ្ជូននឹងមិនត្រូវបានផ្តល់ជូនឡើយប្រសិនបើសេវាកម្មមិនត្រូវបានធានារ៉ាប់រងដោយ LIBERTY ។ បញ្ជីរាយឈ្មោះនៃសេវាកម្មដែលត្រូវបានធានារ៉ាប់រងគឺមាននៅក្នុងកូនសៀវភៅសមាជិកនេះ។

តម្លៃចំណាយរបស់សមាជិក

មិនមានតម្លៃចំណាយឡើយពេលការដឹកជញ្ជូនត្រូវបានអនុញ្ញាតផ្តល់សិទ្ធិដោយគម្រោង LIBERTY ។

ការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ

អ្នកអាចប្រើប្រាស់សេវាកម្មដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ (NMT) នៅពេលដែលអ្នកកំពុង:

- ការធ្វើដំណើរទៅនិងមកពីការណាត់ជួបសម្រាប់សេវា LIBERTY ដែលត្រូវបានគ្របដណ្តប់តាមវេជ្ជបញ្ជារបស់អ្នកផ្តល់សេវារបស់អ្នក។

LIBERTY អនុញ្ញាតឱ្យអ្នកប្រើឡាន តាក់ស៊ី ឡានក្រុងឬមធ្យោបាយសាធារណៈ / ឯកជនផ្សេងទៀតដើម្បីទទួលបានការណាត់ជួបផ្នែកវេជ្ជសាស្ត្ររបស់អ្នកសម្រាប់សេវាវេជ្ជសាស្ត្រដែលមានការគ្របដណ្តប់ដោយរាប់បញ្ចូលទាំងការទូទាត់សំណងនៅពេលដែលការដឹកជញ្ជូនស្ថិតនៅក្នុងរថយន្តឯកជនដែលរៀបចំដោយអ្នកទទួលផលនិងមិនមែនតាមរយៈឈ្មួញដើងសាដឹកជញ្ជូន សំបុត្រឡានក្រុង ប័ណ្ណទូទាត់តាក់ស៊ីឬសំបុត្ររថភ្លើង។ LIBERTY ផ្តល់នូវប្រភេទ NMT ដែលមានតម្លៃទាបបំផុត សម្រាប់តម្រូវការវេជ្ជសាស្ត្ររបស់អ្នកដែលអាចរកបាននៅពេលណាត់ជួបរបស់អ្នក។

ដើម្បីស្នើរសុំសេវា NMT សូមទូរស័ព្ទទៅកាន់ LIBERTY តាមលេខ 888-703-6999 ឬ យ៉ាងហោចណាស់ 10 ថ្ងៃធ្វើការ (ថ្ងៃចន្ទដល់ថ្ងៃសុក្រ) មុនពេលធ្វើការណាត់ជួបឬហៅទូរស័ព្ទឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននៅពេលអ្នកមានការណាត់ជួបជាបន្ទាន់។ សូមត្រៀមប័ណ្ណសម្គាល់សមាជិករបស់អ្នកឱ្យបានរួចរាល់នៅពេលអ្នកហៅទូរស័ព្ទ។

ដែនកម្រិតកំណត់នៃសេវាកម្ម NMT

មិនមានកម្រិតកំណត់សម្រាប់ការទទួលបាននូវ NMT ទៅកាន់ឬមកពីការណាត់ជួបទន្ទសាស្ត្រដែលត្រូវបានធានារ៉ាប់រងនៅក្រោមគម្រោង LIBERTY ឡើយនៅពេលដែលអ្នកផ្តល់សេវាកម្មបានចេញវេជ្ជបញ្ជាវាសម្រាប់អ្នក។

តើអ្វីដែលមិនអាចអនុវត្តន៍បាន?

NMT មិនអាចអនុវត្តន៍បានទេ ប្រសិនបើ:

- រថយន្តសង្គ្រោះបន្ទាន់ រថយន្តវ៉ែងទេសចរណ៍បំពាក់ដោយត្រែស្នែងអ្នកជំងឺរថយន្តមានរទេះរុញ ឬទម្រង់ដទៃទៀតនៃ NEMT មានភាពចាំបាច់ ផ្នែកវេជ្ជសាស្ត្រដើម្បីបានទៅដល់សេវាកម្មដែលត្រូវបានធានារ៉ាប់រង។
- សេវាកម្មនេះមិនត្រូវបានធានារ៉ាប់រងដោយ LIBERTY ឡើយ។ បញ្ជីរាយឈ្មោះនៃសេវាកម្មដែលត្រូវបានធានារ៉ាប់រងគឺមាននៅក្នុងកូនសៀវភៅសមាជិកនេះ។

តម្លៃចំណាយរបស់សមាជិក

មិនមានតម្លៃចំណាយទេ នៅពេលដែលការដឹកជញ្ជូនត្រូវបានអនុញ្ញាតដោយ LIBERTY ។

អ្វីដែលគម្រោងធានារ៉ាប់រងទន្តសាស្ត្ររបស់អ្នកមិនធានារ៉ាប់រង

សេវាសុខភាពធ្មេញដែលទទួលបានខាងក្រៅ ខោនធី Los Angeles
មិនត្រូវបានគ្របដណ្តប់ទេលុះត្រាតែវាជាអាសន្ន។

កម្មវិធី Medi-Cal មិនធានារ៉ាប់រងសេវាកម្មទន្តសាស្ត្រទាំងនេះទេ នៅពេលលើសពីអាយុ 21 ឆ្នាំ:

- ការស្រោបធ្មេញដែលមានលោហៈតម្លៃខ្ពស់ (មាស)
- ប្រព័ន្ធលំហូរធាតុរាវនៃអញ្ចាញ
- ជាតធ្មេញសិប្បនិម្មិតមិនពេញក្រាស់ដែលអាចបត់បែនបាន
- ការពិគ្រោះជាមួយទន្តបណ្ឌិតឯកទេស
- ការរៀបចំព្យាបាលមុនការព្យាបាលធ្មេញ (ដង្កៀប)
- ការ
  ស្រោបពិសោធន៍នៅលើធ្មេញក្រោយដែលមិនគាំទ្រនិងការថែទាំដែលមានស្រាប់ឬធ្មេញពាក់ដើម្បីព្យាបាល
- ក្រាសធ្មេញពាក់តាមផ្នែកលើកលែងតែពេល
  ដែលមានការថែទាំដែលមានស្រាប់ឬការព្យាបាលដែលត្រូវបានគ្រោងទុកសម្រាប់ក្រាសធ្មេញពាក់
  នៅជួរផ្សេងទៀត។
- ការដាំបង្គោលធ្មេញនិងសេវាកម្មទាក់ទងការដាំបង្គោលធ្មេញលុះត្រាតែមានសភាពវេជ្ជសាស្ត្រដែល
  លើកលែង។
- ធ្មេញសិប្បនិម្មិតមិនពេញក្រាស់ដែលអចល័ត (ធ្មេញស្ពានតំណ) លុះត្រាតែ
  មានសភាពវេជ្ជសាស្ត្រដែលលើកលែង។

ប្រសិនបើអ្នកមានសំណួរឬចង់ស្វែងយល់បន្ថែមអំពីសេវាកម្មទន្តសាស្ត្ររ
សូមហៅទូរស័ព្ទមកកម្មវិធី Denti-Cal តាមរយៈលេខទូរស័ព្ទ 1-800-322-6384 (TTY 1-800-735-2922)។ អ្នកក៏អាចនឹងចូលទៅកាន់គេហទំព័ររបស់កម្មវិធី Denti-Cal នៅអាសយដ្ឋាន denti-cal.ca.gov បានផងដែរ។

សេវាកម្មដែលអ្នកមិនអាចទទួលបានតាមរយៈគម្រោង LIBERTY ឬកម្មវិធី Medi-Cal

មានសេវាកម្មមួយចំនួនដែលទាំងគម្រោងធានារ៉ាប់រង LIBERTY ទាំងកម្មវិធី Medi-Cal
នឹងមិនធានារ៉ាប់រង ដែលរួមមាន:

- សេវាកម្មកុមាររដ្ឋCalifornia (CCS)
- សេវាកម្មពាក់ព័ន្ធនឹងអ្វីដែលមិនមែនទន្តសាស្ត្ររ
- សេវាកម្មសុខភាពធ្មេញណាមួយដែលមិនត្រូវបាន ក្របដណ្តប់ដោយកម្មវិធី Medi-Cal Dental
- សេវាកម្មសុខភាពមាត់ធ្មេញដែលបានចាប់ផ្តើមមុនពេលធានាការរ៉ាប់រង
  ឬបន្ទាប់ពីការបញ្ចប់នៃការធានារ៉ាប់រងជាមួយគម្រោង

- សេវាកម្មសុខភាពមាត់ធ្មេញ ទម្រង់ការបរិធានឬការស្តារត្រលប់មកវិញដើម្បីព្យាបាលរបិត្តិមុខងារសន្លាក់នៅចន្លោះថ្គាមនិងសៀតថ្គា (TMJ)
- សេវាកម្មសុខភាពធ្មេញដែលត្រូវបានកំណត់សម្រាប់គោលបំណងកែសម្ផស្សដោយផ្អែកលើការពិនិត្យឡើងវិញដោយអ្នកមានវិជ្ជាជីវៈ
- សេវាកម្មសុខភាពធ្មេញដែលត្រូវបានកំណត់ថាមិនមានភាពចាំបាច់សម្រាប់សុខភាពធ្មេញតាមការពិនិត្យដោយអ្នកមានវិជ្ជាជីវៈ
- សេវាសុខភាពមាត់ធ្មេញដើម្បីជួសជុលរចនាសម្ព័ន្ធធ្មេញដែលបាត់បង់ពីការកកិត សំណឹក ក្រដុសធ្មេញឬការខាំធ្មេញ
- សេវាកម្មសុខភាពធ្មេញឬឧបករណ៍ប្រើប្រាស់ដែលត្រូវបានផ្តល់ដោយទន្តបណ្ឌិតដែលមានឯកទេសខាងសរីរាង្គធ្មេញសិប្បនិម្មិត។
- សេវាសុខភាពធ្មេញសម្រាប់ការយកធ្មេញថ្នាមទីបី (ធ្មេញប្រាជ្ញា) ដែលមិនមានសញ្ញានៃការពុកផុយ ការឈឺចាប់មិនអាចបញ្ឈប់បាននិងការឆ្លងមេរោគ និង/ឬធ្មេញដែលមិនរារាំងការដុះចេញនៃធ្មេញផ្សេងទៀត។
- សេវាសុខភាពធ្មេញដែលនឹងផ្លាស់ប្តូរទម្រង់ធ្មេញពេលខាំនិងទំពារ
- សេវាកម្មសុខភាពធ្មេញណាមួយដែលត្រូវបានធ្វើឡើងនៅខាងក្រៅការិយាល័យទន្តសាស្ត្រដែលត្រូវបានចាត់តាំងសម្រាប់អ្នក លុះត្រាតែត្រូវបានអនុញ្ញាតផ្តល់សិទ្ធិយ៉ាងច្បាស់លាស់ដោយគម្រោងធានារ៉ាប់រង LIBERTY។
- សេវាកម្មទន្តសាស្ត្រជាប្រចាំណាមួយដែលត្រូវបានធ្វើឡើងដោយទន្តបណ្ឌិតឬទន្តបណ្ឌិតឯកទេសនៅក្នុងបរិបទស្ថាប័នមន្ទីរពេទ្យបែបពិគ្រោះជំងឺក្នុង/ពិគ្រោះជំងឺក្រៅ

សូមអានផ្នែកនីមួយៗខាងក្រោម ដើម្បីស្វែងយល់បន្ថែម។ ឬទូរស័ព្ទទៅ 888-703-6999 (TTY 800-735-2929) ។

សេវាកម្មកុមាររដ្ឋCalifornia (CCS)

CCS គឺជាកម្មវិធីរបស់រដ្ឋដែលព្យាបាលកុមារអាយុក្រោម 21 ឆ្នាំដែលមានលក្ខខណ្ឌសុខភាពជំងឺឬបញ្ហាសុខភាពរ៉ាំរ៉ៃជាក់លាក់មួយចំនួន ហើយកុមារនោះបានគោរពតាមគោលការណ៍កម្មវិធីរបស់ CCS ។ ប្រសិនបើ LIBERTY ឬ PCP របស់អ្នកជឿថាកូនរបស់អ្នកមានសភាពជំងឺ CCS គាត់នឹងត្រូវបានបញ្ជូនបន្តទៅកាន់កម្មវិធី CCS។

បុគ្គលិកកម្មវិធី CCS នឹងសំរេចថាតើកូនរបស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សេវាកម្ម CCS ដែរឬទេ។ ប្រសិនបើកូនរបស់អ្នកអាចទទួលបានការថែទាំបែបនេះ អ្នកផ្តល់សេវា CCS នឹងព្យាបាលគាត់ឬនាងសម្រាប់ស្ថានភាពជំងឺ CCS ។ LIBERTY នឹងបន្តគ្របដណ្តប់លើប្រភេទនៃសេវាកម្មដែលមិនទាក់ទងនឹងលក្ខខណ្ឌ CCS ដូចជាលំហាត់ប្រាណ ថ្នាំបង្ការនិងការពិនិត្យសុខភាពកុមារ។

LIBERTY មិនធានារ៉ាប់រងលើការថែទាំដែលត្រូវបានផ្តល់ជូនដោយកម្មវិធី CCS ឡើយ។ ដើម្បីឱ្យកម្មវិធី CCS ធានារ៉ាប់រងលើបញ្ហាទាំងនេះ កម្មវិធី CCS ត្រូវតែឯកភាពអនុម័តអ្នកផ្តល់សេវាកម្ម សេវាកម្មនិងបរិក្ខារ។

កម្មវិធី CCS មិនធានារ៉ាប់រងរាល់ក្រុមជម្ងឺទាំងអស់ទេ។ CCS ក្រុមដណ្តប់លើជម្ងឺ
សុខភាពភាគច្រើនដែលធ្វើឱ្យពិការខាងរាងកាយឬដែលត្រូវការការព្យាបាលដោយប្រើឱសថ
ការវះកាត់ឬការស្តារនីតិសម្បទា(ស្តារសមត្ថភាព)។ កម្មវិធី CCS ធានារ៉ាប់រងកុមារដែល
មានជម្ងឺដូចជា៖

- ជំងឺបេះដូងពីកំណើត
- ជំងឺមហារីក
- ដុំសាច់មិនធម្មតា
- ជំងឺឈាមក្រហម
- ជំងឺគោលិកក្រហមរាងកណ្តៀរ
- ជម្ងឺក្រពេញថាយរ៉យ
- ជំងឺទឹកនោមផ្អែម
- ជម្ងឺតម្រងនោមរ៉ាំរ៉ៃធ្ងន់ធ្ងរ
- ជំងឺថ្លើម
- ជំងឺពោះវៀន
- ជម្ងឺមាត់/ក្រអូមមាត់ឆែប
- ជំងឺឆ្អឹងខ្នងមានប្រហោងបិទមិនជិត
- ជំងឺបាត់បង់ការស្តាប់លឺ
- ជំងឺភ្នែកឡើងបាយ
- ជំងឺខ្វិនពិការដោយសារសរសៃប្រសាទរងការខូចខាត
- ជំងឺប្រកាច់ដែលមិនបានគ្រប់គ្រង
- ជំងឺរលាកសន្លាក់ដោយសារប្រព័ន្ធភាពស៊ាំរាងកាយ
- ជំងឺរួញស្ងួតសាច់ដុំ
- ជំងឺអេដស៍
- របួសក្បាល ខួរក្បាលឬឆ្អឹងខ្នងធ្ងន់ធ្ងរ
- រលាកធ្ងន់ធ្ងរ
- ធ្មេញកោងខុបធ្ងន់ធ្ងរ

រដ្ឋបង់ប្រាក់ជូនសម្រាប់សេវាកម្មក្នុងកម្មវិធី CCS។ ប្រសិនបើកូនរបស់អ្នក
មិនមានសិទ្ធិសាកសមទទួលបានសេវាកម្មក្នុងកម្មវិធី CCS ទេ គេនឹងនៅបន្តទទួលបានការ
ថែទាំដែលមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រពី LIBERTY ដ៏ដែល។

ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធី CCS សូមទូរស័ព្ទមកលេខ 888-703-6999 (TTY 800-735-2929)។

ការសម្របសម្រួលអត្ថប្រយោជន៍

LIBERTY ផ្តល់សេវាកម្មនានា ដើម្បីជួយអ្នកឱ្យសម្របសម្រួល
តម្រូវការថែទាំទន្តសាស្ត្ររបស់អ្នកដោយមិនគិតថ្លៃពីអ្នក។
ប្រសិនបើអ្នកមានសំណួរឬក្តីកង្វល់ផ្សេងៗអំពីការថែទាំទន្តសាស្ត្ររបស់អ្នក
ឬការថែទាំទន្តសាស្ត្រកូនរបស់អ្នក សូមទូរស័ព្ទទៅលេខ 888-703-6999 (TTY 800-735-2929)។

5. សិទ្ធិនិងទំនួលខុសត្រូវ

ក្នុងនាមជាសមាជិកម្នាក់របស់ LIBERTY អ្នកមានសិទ្ធិ
និងទំនួលខុសត្រូវជាក់លាក់មួយចំនួន។ ជំពូកនេះនឹងពន្យល់អំពីសិទ្ធិនិងទំនួលខុសត្រូវ
ទាំងនោះ។ ជំពូកនេះក៏នឹងផ្តល់ជូនផងដែរនូវសេចក្តីជូនដំណឹងផ្លូវច្បាប់ដែលអ្នកមានសិទ្ធិ
ទទួលបានក្នុងនាមជាសមាជិករបស់ LIBERTY។

សិទ្ធិរបស់អ្នក

សមាជិកគម្រោង LIBERTYមានសិទ្ធិទាំងនេះ៖

- ត្រូវបានព្យាបាលដោយការគោរពដោយពិចារណាដោយយកចិត្តទុកដាក់ចំពោះសិទ្ធិឯកជនភាពរបស់សមាជិក
  និងតម្រូវការរក្សាការសម្ងាត់ព័ត៌មានផ្នែកវេជ្ជសាស្ត្រនិងទន្តសាស្ត្ររបស់សមាជិក។
- ត្រូវបានគេផ្តល់ជូននូវព័ត៌មានអំពីគម្រោងនិងសេវាកម្មរបស់វា រួម
  ទាំងសេវាដែលមានការគ្របដណ្តប់
- អាចជ្រើសរើសទន្តបណ្ឌិតថែទាំសុខភាពបឋមនៅក្នុងបណ្តាញរបស់អ្នកចុះកិច្ចសន្យា
- ចូលរួមក្នុងការសម្រេចចិត្តទាក់ទងនឹងការថែរក្សាសុខភាពផ្ទេញរបស់ពួកគេរួមទាំងសិទ្ធិ
  ក្នុងការបដិសេធការព្យាបាល។
- ដាក់ពាក្យបណ្តឹងសារទុក្ខដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរអំពីអង្គការ
  ឬការថែទាំដែលទទួលបាន។
- ទទួលបានសេវាបកប្រែភាសាផ្ទាល់មាត់សម្រាប់ភាសារបស់ពួកគេ។
- មានលទ្ធភាពចូលទៅកាន់មណ្ឌលសុខភាពមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
  ទទួលស្គាល់ដោយសហព័ន្ធ ស្ថាប័នសេវាកម្មសុខភាពជនជាតិដើមភាគតិចក្រហម
  និងសេវាកម្មសង្គ្រោះបន្ទាន់នៅក្រៅបណ្តាញអ្នកចុះកិច្ចសន្យាផ្តល់សេវាដោយអនុលោម
  តាមច្បាប់សហព័ន្ធ។
- ស្នើសុំសវនាការថ្នាក់រដ្ឋ រួមមានព័ត៌មានស្តីអំពីកាលៈទេសៈនានាដែលនៅក្រោម
  នោះសវនាការឆាប់រហ័សអាចប្រព្រឹត្តទៅបាន។
- មានលទ្ធភាពប្រើប្រាស់និងទទួលបានច្បាប់ចម្លង
  ផ្លាស់ប្តូរឬកែប្រែកំណត់ត្រាផ្ទេញរបស់ពួកគេពេលច្បាប់អនុញ្ញាត។
- លុបឈ្មោះចេញតាមការស្នើរសុំ។

- ទទួលបានឯកសារព័ត៌មានសម្រាប់សមាជិកក្នុងទម្រង់ជំនួស (រួមមានអក្សរធំតសម្រាប់ជនពិការភ្នែក អក្សរពុម្ពធំនិងទម្រង់ជាអូឌីយ៉ូ) តាមការស្នើរសុំនិងទាន់ពេលវេលាសមស្របសម្រាប់ទម្រង់ដែលបានស្នើសុំនិងស្របតាមក្រមច្បាប់ W & I Code Section 14182 (b) (12)។
- មិនត្រូវទទួលឥទ្ធិពលពីការរាំងស្ទះឬភាពឯការដែលត្រូវបានគេប្រើជាមធ្យោបាយនៃការបង្ខិតបង្ខំ ការដាក់វិន័យ ភាពងាយស្រួលឬការសងសឹក។
- ទទួលព័ត៌មានអំពីជម្រើសនៃការព្យាបាលដែលអាចរកបាន និងជម្រើសជំនួសដែលត្រូវបានបង្ហាញតាមលក្ខណៈសមស្របទៅនឹងស្ថានភាព និងសមត្ថភាពរបស់សមាជិក។
- ដើម្បីទទួលបានច្បាប់ចម្លងកំណត់ត្រាសុខភាពធ្មេញរបស់គាត់ ហើយស្នើរសុំឱ្យពួកគេកែប្រែឬកែតម្រូវតាមបទបញ្ជារបស់សហព័ន្ធ។
- សេរីភាពក្នុងការប្រើប្រាស់សិទ្ធិទាំងនេះដោយមិនប៉ះពាល់ដល់របៀបដែលអ្នកម៉ៅការសេវា អ្នកផ្តល់សេវាឬរដ្ឋប្រព្រឹត្តចំពោះពួកគេ។

ទំនួលខុសត្រូវរបស់អ្នក

LIBERTYមានទំនួលខុសត្រូវដូចខាងក្រោម៖

- ផ្តល់ដល់ទន្តបណ្ឌិតរបស់អ្នក តាមការយល់ដឹងដ៏ប្រសើរបំផុតរបស់អ្នក នូវព័ត៌មានត្រឹមត្រូវអំពីសុខភាពរាងកាយនិងធ្មេញរបស់អ្នក។
- ប្រាប់ទន្តបណ្ឌិតរបស់អ្នក ប្រសិនបើអ្នកមានការប្រែប្រួលរហ័សភ្លាមៗណាមួយ ទៅលើសុខភាពរាងកាយនិងធ្មេញរបស់អ្នក។
- ប្រាប់ទន្តបណ្ឌិតរបស់អ្នកថាអ្នកយល់អំពីផែនការព្យាបាលនិងអ្វីដែលអ្នកត្រូវការ
- បន្តនៅជាមួយផែនការព្យាបាលដែលអ្នកយល់និងបានយល់ព្រមជាមួយទន្តបណ្ឌិតរបស់អ្នក
- គោរពតាមការណាត់ជួបដែលត្រូវបានគ្រោងទុករបស់អ្នកជាមួយទន្តបណ្ឌិតរបស់អ្នក
- ប្រាប់ឱ្យទន្តបណ្ឌិតរបស់អ្នកដឹងជាមុនប្រសិនបើអ្នកមិនអាចទៅកាន់ការណាត់ជួបដែលបានគ្រោងទុករបស់អ្នក
- ទង្វើប្រព្រឹត្តរបស់ខ្លួនអ្នកផ្ទាល់ប្រសិនបើអ្នកបដិសេធការព្យាបាលឬមិនអនុវត្តន៍តាមសេចក្តីណែនាំ ដំបូន្មាននិងផែនការព្យាបាលរបស់ទន្តបណ្ឌិតរបស់អ្នក
- ទូទាត់ថ្លៃសេវាកម្មដែលបានព្រមព្រៀងគ្នាឬថវិការទៅឱ្យ ការិយាល័យសុខភាពធ្មេញរបស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន
- គោរពអនុវត្តន៍តាមច្បាប់ក្រិតក្រមរបស់ការិយាល័យសុខភាពធ្មេញទាំងអស់អំពីការថែទាំនិងការប្រតិបត្តិខ្លួន

កំណត់សម្គាល់អំពីការអនុវត្តន៍ឯកជនភាព

សេចក្តីថ្លែងការណ៍មួយដែលរៀបរាប់ពិព៌ណនាអំពីគោលនយោបាយនិង
នីតិវិធីរបស់គម្រោងធានារ៉ាប់រងរបស់យើងសម្រាប់ក្សាការសម្ងាត់
អំពីឯកសារកំណត់ត្រាទន្តសាស្ត្រគឺមានហើយនឹងត្រូវបានផ្តល់ជូនអ្នកតាមសំណើរសុំ។

ដូចដែលតម្រូវទាមទារដោយច្បាប់ សេចក្តីជូនដំណឹងនេះស្តីអំពីសិទ្ធិរបស់អ្នក
ការ:កិច្ចផ្លូវច្បាប់និងការអនុវត្តន៍ឯកជនភាពរបស់យើងទាក់ទងនឹងឯកជនភាព
នៃព័ត៌មានសុខភាពផ្ទាល់ខ្លួន (PHI)។
សេចក្តីជូនដំណឹងនេះក៏និយាយផងដែរអំពីវិធីដែលយើងខ្ញុំអាចនឹងប្រមូលយក
ប្រើប្រាស់និងបើកទម្លាយ PHI របស់អ្នក។
យើងខ្ញុំត្រូវអនុវត្តន៍តាមសេចក្តីបង្គាប់នៃសេចក្តីជូនដំណឹងដែលកំពុងមានប្រ
សិទ្ធិភាពជាធរមាននាពេលបច្ចុប្បន្ន។
យើងខ្ញុំរក្សាសិទ្ធិក្នុងការកែប្រែទៅលើសេចក្តីជូនដំណឹងនេះនៅពេលមួយ និងធ្វើឱ្យ
សេចក្តីជូនដំណឹងដែលត្រូវបានផ្លាស់ប្តូរមានប្រសិទ្ធិភាពជាធរមាន សម្រាប់ PHI
ទាំងអស់ដែលយើងខ្ញុំរក្សាទុក។ អ្នកអាចរកសេចក្តីជូនដំណឹងស្តីអំពីឯកជនភាពថ្មីបំផុត
របស់យើងខ្ញុំបាន នៅលើគេហទំព័ររបស់យើងខ្ញុំនៅអាសយដ្ឋាន www.libertydentalplan.com។

សូមហៅទូរស័ព្ទមកផ្នែកសេវាកម្មសមាជិករបស់យើងខ្ញុំ តាមរយ:លេខ 888-703-6999 (TTY 800-735-2929) ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ដើម្បីទទួលច្បាប់សំណៅចម្លងជាលាយលក្ខណ៍អក្សរ
នេះសេចក្តីជូនដំណឹងនេះ។

កំណត់សម្គាល់អំពីច្បាប់

ច្បាប់ជាច្រើនត្រូវបានអនុវត្តចំពោះកូនសៀវភៅណែនាំសមាជិកនេះ ច្បាប់ទាំងនេះអាចនឹង
មានមានឥទ្ធិពលប៉ះពាល់ទៅលើសិទ្ធិនិងទំនួលខុសត្រូវ របស់អ្នកបើទោះបីជា
ច្បាប់ទាំងនេះមិនត្រូវបានដាក់បញ្ចូល ឬពន្យល់នៅក្នុងសៀវភៅណែនាំនេះក៏ដោយ។
ច្បាប់ចម្បងដែលត្រូវបានអនុវត្តចំពោះសៀវភៅណែនាំនេះ គឺច្បាប់រដ្ឋ និងច្បាប់សហព័ន្ធស្តីអំពី
កម្មវិធី Medi-Cal។ ច្បាប់សហព័ន្ធ និងច្បាប់រដ្ឋដទៃទៀតក៏អាចនឹងត្រូវអនុវត្តន៍ផងដែរ។

កំណត់សម្គាល់អំពីកម្មវិធី Medi-Cal ក្នុងនាមជាអ្នកបង់ប្រាក់ជម្រើសចុងក្រោយ។

ជួនកាល មានមនុស្សម្នាក់ទៀតត្រូវទូទាត់ប្រាក់ជាមុនសម្រាប់សេវាកម្មទាំងឡាយណាដែល
យើងខ្ញុំបានផ្តល់ជូនអ្នក។ ឧទាហរណ៍ ប្រសិនបើអ្នកមានការធានារ៉ាប់រងសុខភាពដែលមានតម្លៃ
សមរម្យពីនិយោជករបស់អ្នក។

ក្នុងនាមជាសមាជិក LIBERTY អ្នកនឹងទទួលបានអត្ថប្រយោជន៍ Medi-Cal របស់អ្នកជានិច្ច។
ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកមានការធានារ៉ាប់រងក្រោមគម្រោង
ឬគោលនយោបាយពីគម្រោងសុខភាពផ្សេងទៀត ការគ្របដណ្តប់របស់អ្នកក្រោមគម្រោង
នេះគឺជាផលប្រយោជន៍សុខភាពធ្នើញទីពីរ។

ក្រសួងសេវាកម្មថែទាំសុខភាពរដ្ឋCaliforniaមានសិទ្ធិ និងទំនួលខុសត្រូវ ក្នុងការប្រមូលប្រាក់សម្រាប់សេវាកម្មកម្មវិធី Medi-Cal ដែលត្រូវបានធានារ៉ាប់រងដែលសម្រាប់វានេះកម្មវិធី Medi-Cal មិនមែនជាអ្នកបង់ផ្ទែទូទាត់ដំបូងទេ។

កម្មវិធី Medi-Cal គោរពតាមច្បាប់រដ្ឋនិងច្បាប់សហព័ន្ធនិងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងទំនួលខុសត្រូវផ្លូវច្បាប់របស់ភាគីទីបី ចំពោះសេវាកម្មថែទាំសុខភាពដល់អ្នកទទួលផល។ យើងខ្ញុំនឹងចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាឱ្យប្រាកដថា កម្មវិធី Medi-Cal គឺជាអ្នកបង់ប្រាក់ជម្រើសចុងក្រោយ។

កំណត់សម្គាល់អំពីការកំណត់អត្តប្រយោជន៍ដែលមានលក្ខណៈមិនអំណោយផល

យើងខ្ញុំត្រូវតែប្រើប្រាស់ទម្រង់បែបបទនៃកំណត់សម្គាល់អំពីការកំណត់អត្តប្រយោជន៍ដែលមានលក្ខណៈមិនអំណោយផល (NABD) ដើម្បីជូនដំណឹងដល់អ្នកអំពីការបដិសេធ ការបញ្ចប់ និងការពន្យាអូសបន្លាយពេល ឬការកែប្រែនៅលើអត្តប្រយោជន៍។ ប្រសិនបើអ្នកមិនយល់ព្រមនឹងសេចក្តីសម្រេចរបស់យើងខ្ញុំទេ អ្នកអាចដាក់ពាក្យប្តឹងឧទ្ធរណ៍ជាមួយគម្រោងយើងខ្ញុំបាន។

6. ការរាយការណ៍និងការដោះស្រាយបញ្ហា

មានបញ្ហាពីរប្រភេទដែលអ្នកអាចនឹងមានជាមួយគម្រោងធានារ៉ាប់រងទន្តសាស្ត្រ:

- **ពាក្យបណ្តឹង** (ឬ **បណ្តឹងសារទុក្ខ)** គឺនៅពេលដែលអ្នកមានបញ្ហាជាមួយ LIBERTY ឬអ្នកផ្តល់សេវាណាមួយ ឬជាមួយនឹងការថែទាំសុខភាពធ្មេញឬការព្យាបាលដែលអ្នកទទួលបានពីអ្នកផ្តល់សេវា
- **បណ្តឹងឧទ្ធរណ៍** គឺនៅពេលដែលអ្នកមិនឯកភាពជាមួយសេចក្តីសម្រេចរបស់ LIBERTY ក្នុងការមិនធានារ៉ាប់រងទៅលើសេវាកម្ម។

អ្នកគួរប្រើប្រាស់ដំណើរការបណ្តឹងសារទុក្ខនិងបណ្តឹងឧទ្ធរណ៍ របស់គម្រោងធានារ៉ាប់រង LIBERTY ជាមុនសិន ដើម្បីអនុញ្ញាតឱ្យយើងខ្ញុំដឹងអំពីបញ្ហារបស់អ្នក។ ប្រការនេះមិនដកយកចេញសិទ្ធិស្របច្បាប់ណាមួយ និងដំណោះស្រាយកែតម្រូវណាមួយរបស់អ្នកទេ យើងខ្ញុំក៏នឹងមិនរើសអើងឬសងសឹកប្រឆាំងនឹងអ្នកដែរសម្រាប់ការប្តឹងតវ៉ាមកកាន់យើងខ្ញុំ។ ការឱ្យយើងខ្ញុំដឹងអំពីបញ្ហារបស់អ្នកនឹងជួយយើងខ្ញុំឱ្យកែលម្អការថែទាំសម្រាប់សមាជិកគ្រប់រូបទាំងអស់។ ប្រសិនបើបណ្តឹងសារទុក្ខរបស់អ្នកមិនត្រូវបានដោះស្រាយទេ អ្នកអាចនឹងដាក់ពាក្យបណ្តឹងជាមួយក្រសួងទទួលបន្ទុកការថែទាំសុខភាពដោយមានការគ្រប់គ្រង (DMHC) បាន។ ប្រសិនបើអ្នកមិនយល់ស្របជាមួយនឹងលទ្ធផលនៃបណ្តឹងឧទ្ធរណ៍ អ្នកអាចដាក់ពាក្យបណ្តឹងស្នើរសុំសវនាការយុត្តិធម៌ថ្នាក់រដ្ឋបាន។ អ្នកត្រូវបំពេញតាមដំណើរការបណ្តឹងឧទ្ធរណ៍របស់ LIBERTY មុនពេលអ្នកអាចដាក់ពាក្យបណ្តឹងសវនាការយុត្តិធម៌ថ្នាក់រដ្ឋបាន។

អ្នកក៏អាចនឹងស្នើសុំការត្រួតពិនិត្យសើរើផ្នែកវេជ្ជសាស្ត្រឯករាជ្យ (IMR) ពីក្រសួង DMHC ផងដែរ។ IMR គឺជាការត្រួតពិនិត្យសើរើឡើងវិញមិនលម្អៀងនៃ សេចក្តីសម្រេចផ្នែកទន្តសាស្ត្ររបស់គម្រោង។ IMR សម្រេចចិត្តអំពីភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ ការធានារ៉ាប់រង និងវិវាទការបង់ប្រាក់សម្រាប់សេវាបន្ទាន់ឬគ្រាអាសន្ន។ អ្នកត្រូវស្នើសុំ IMR ក្នុងកំឡុងពេល 6 ខែ បន្ទាប់ពី LIBERTY ផ្ញើជូនអ្នក នូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរអំពីបណ្តឹងឧទ្ធរណ៍របស់អ្នក។

ប្រសិនបើអ្នកស្នើសុំសវនាការថ្នាក់រដ្ឋមុន នោះអ្នក **មិនអាច** ស្នើរសុំការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យ (IMR) បាននោះទេ ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកស្នើសុំ IMR មុន ហើយមិនពេញចិត្តនឹងលទ្ធផល អ្នកអាចស្នើសុំសវនាការថ្នាក់រដ្ឋបាន។ អ្នកអាចទទួលបានជំនួយពីក្រសួងទទួលបន្ទុកការថែទាំសុខភាពដោយមានការគ្រប់គ្រងនៃរដ្ឋ Californiaបាន។

ក្រសួងទទួលបន្ទុកការថែទាំសុខភាពដោយមានការគ្រប់គ្រងនៃរដ្ឋ California ទទួលខុសត្រូវចំពោះការធ្វើនិយ័តកម្មគម្រោងធានារ៉ាប់រងសេវាកម្មថែទាំសុខភាព។ ប្រសិនបើអ្នកកើតទុក្ខមិនសុខចិត្តនឹងគម្រោងធានារ៉ាប់រងសុខភាពរបស់អ្នក អ្នកគួរតែទូរស័ព្ទមកគម្រោងធានារ៉ាប់រងសុខភាពរបស់អ្នក តាមរយៈលេខ **888-703-6999 (TTY: 800-735-2929)** ហើយប្រើប្រាស់ដំណើរការបណ្តឹងសារទុក្ខរបស់គម្រោងធានារ៉ាប់រងសុខភាពរបស់អ្នក មុនទាក់ទងទៅក្រសួងនោះ។ ការប្រើនីតិវិធីបណ្តឹងសារទុក្ខនេះមិនបានរារាំងទប់ស្កាត់សិទ្ធិផ្លូវច្បាប់ឬដំណោះស្រាយកែតម្រូវជាសក្តានុពលដែលអាចនឹងមានសម្រាប់រូបអ្នកនោះឡើយ។ ប្រសិនបើអ្នកត្រូវការជំនួយសម្រាប់បណ្តឹងសារទុក្ខណាមួយពាក់ព័ន្ធនឹងករណីសង្គ្រោះបន្ទាន់ បណ្តឹងសារទុក្ខដែលមិនត្រូវបានគម្រោងធានារ៉ាប់រងសុខភាពរបស់អ្នកដោះស្រាយ ប្រកបដោយការពេញចិត្ត ឬបណ្តឹងសារទុក្ខដែលនៅមិនទាន់ត្រូវបានដោះស្រាយអស់រយៈពេលលើសពី 30 ថ្ងៃហើយ អ្នកអាចនឹងទូរស័ព្ទទៅក្រសួងដើម្បីទទួលបាន ជំនួយ។ អ្នកក៏អាចនឹងមានសិទ្ធិសាកសមទទួលបានការត្រួតពិនិត្យសើរើវេជ្ជសាស្ត្រឯករាជ្យ (IMR) ផងដែរ។ ប្រសិនបើអ្នកមានសិទ្ធិសាកតសមទទួលបាន IMR ដំណើរការ IMR នោះនឹងផ្តល់ការត្រួតពិនិត្យសើរើឡើងវិញដោយឥតលម្អៀងលើសេចក្តីសម្រេចវេជ្ជសាស្ត្រដែលធ្វើឡើងដោយគម្រោងធានារ៉ាប់រងសុខភាពទាក់ទងនឹងភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រនៃសេវាកម្ម ឬការព្យាបាលដែលបានស្នើឡើង សេចក្តីសម្រេចខាងធានារ៉ាប់រងសម្រាប់ការព្យាបាលដែលមានសភាវៈជាការដកពិសោធន៍ ឬការស៊ើបអង្កេតនិងវិទក្នុងរឿងទូទាត់ប្រាក់សម្រាប់សេវាកម្មវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ឬបន្ទាន់។ នាយកដ្ឋានក៏មានលេខទូរស័ព្ទឥតគិតថ្លៃមួយចំនួនផងដែរគឺលេខ **(1-888-HMO-2219)** និងខ្សែទូរស័ព្ទ TDD **(1-877-688-9891)** សម្រាប់អ្នកគថ្លង់។ គេហទំព័រលើអ៊ីនធឺណិតរបស់ក្រសួង **http://www.hmohelp.ca.gov** មានទម្រង់បែបបទបណ្តឹងតវ៉ា ពាក្យស្នើសុំ IMR និងសេចក្តីណែនាំនៅលើអ៊ីនធើណិត។

មន្ត្រីស៊ើបអង្កេតបណ្តឹងរបស់កម្មវិធីថែទាំសុខភាពដោយមានការគ្រប់គ្រង Medi-Cal នៃក្រសួងសេវាកម្មថែទាំសុខភាពនៃរដ្ឋ Californiaក៏អាចជួយបានផងដែរ។ មន្ត្រីស៊ើបអង្កេតបណ្តឹងអាចជួយជាមួយនឹងបញ្ហាដែលគម្រោងមិនទាន់បានដោះស្រាយ បញ្ហាក្នុងការចូលរួមជាមួយ ផ្លាស់ប្តូរ ឬចាកចេញពីគម្រោង និងបញ្ហាដទៃផ្សេងៗទៀតជាមួយនឹងគម្រោងថែទាំដោយមានការគ្រប់គ្រង Medi-Cal។ អ្នកអាចទូរស័ព្ទទៅមន្ត្រីស៊ើបអង្កេតបណ្តឹងតាមរយៈលេខ **1-888-452-8609** ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8:00 ព្រឹក to 5:00 ល្ងាច។

អ្នកក៏អាចដាក់ពាក្យបណ្តឹងសារទុក្ខជាមួយការិយាល័យទទួលបន្ទុកភាពទទួលបានសិទ្ធិប្រចាំខេត្តរបស់អ្នកអំពីភាពមានសិទ្ធិសាកសមទទួលបាន កម្មវិធី Medi-Cal ផងដែរ។ ប្រសិនបើអ្នកមិនប្រាកដថាអ្នកណាអ្នកអាចដាក់ពាក្យបណ្តឹងសារទុក្ខជាមួយបាន សូមហៅទូស័ព្ទទៅលេខ 888-703-6999 (TTY 800-735-2929)។

បណ្តឹងតវ៉ា

បណ្តឹងតវ៉ា (ឬបណ្តឹងសារទុក្ខ) អាចស្តីអំពីការថែទាំដែលអ្នកទទួលបានពីអ្នកផ្តល់សេវាកម្មថែទាំនៃបណ្តាញ។ ពាក្យបណ្តឹងក៏អាចធ្វើឡើងអំពី LIBERTY ផងដែរ។ សូមមើលផ្នែកខាងក្រោមសម្រាប់ព័ត៌មានបន្ថែមអំពីបណ្តឹងឧទ្ធរណ៍និងសវនាការថ្នាក់រដ្ឋ។ អ្នកអាចដាក់ពាក្យបណ្តឹងជាមួយ PCD របស់អ្នកឬជាមួយ LIBERTY។

អ្នកអាចដាក់ពាក្យបណ្តឹងជាមួយយើងខ្ញុំតាមទូរស័ព្ទ ឬសារអេឡិចត្រូនិក។ មិនមានដែនកម្រិតពេលវេលាដើម្បីដាក់ពាក្យបណ្តឹងតវ៉ានោះឡើយ។

ដើម្បីដាក់ពាក្យបណ្តឹងតាមទូរស័ព្ទ សូមទូរស័ព្ទមកការិយាល័យ PCD ឬហៅទូរស័ព្ទរបស់អ្នកទៅលេខ 888-703-6999 (TTY 800-735-2929) ។ សូមផ្តល់លេខសម្គាល់សមាជិកគម្រោងធានារ៉ាប់រងទន្តសាស្ត្ររបស់អ្នក ឈ្មោះ របស់អ្នកនិងហេតុផលសម្រាប់បណ្តឹងតវ៉ារបស់អ្នក។

ដើម្បីដាក់ពាក្យបណ្តឹងតាមប្រៃសណីយ៍ សូមទូរស័ព្ទទៅលេខ 888-703-6999 (TTY 800-735-2929) ។ ស្នើរសុំឱ្យផ្ញើសំណុំបែបបទមួយច្បាប់ទៅអ្នក។ នៅពេលដែលអ្នកទទួលបានទម្រង់ពាក្យបណ្តឹងរួចហើយ សូមបំពេញវា។ ត្រូវប្រាកដថាបានដាក់បញ្ចូលឈ្មោះ លេខសម្គាល់សមាជិកគម្រោងធានារ៉ាប់
រងទន្តសាស្ត្ររបស់អ្នកនិងហេតុផលសម្រាប់បណ្តឹងតវ៉ារបស់អ្នក។
សូមប្រាប់យើងខ្ញុំនូវអ្វីដែលបានកើតឡើង និងតើយើងខ្ញុំអាចជួយអ្នកបានដោយរបៀបណា។

សូមផ្ញើទម្រង់បែបបទនេះតាមប្រៃសណីយ៍ទៅកាន់៖

LIBERTY Dental Plan
Quality Management Department
340 Commerce, Suite 100
Irvine, CA 92602
Fax: (949) 270-0109

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការដាក់ពាក្យបណ្តឹងរបស់អ្នក យើងអាចជួយ អ្នកបាន។ យើងខ្ញុំអាចផ្តល់ជូនអ្នកនូវសេវាកម្មភាសាដោយឥតគិតថ្លៃ។ សូមទូរស័ព្ទទៅ 888-703-6999 (TTY 800-735-2929) ។

ក្នុងរយៈពេល 5 ថ្ងៃបន្ទាប់ពីទទួលបានពាក្យបណ្តឹង
យើងនឹងផ្ញើលិខិតមួយច្បាប់ឱ្យអ្នកដឹងថាយើងបានទទួលវា។ ក្នុងរង្វង់ពេល 30 ថ្ងៃ
យើងខ្ញុំនឹងប្រាប់អ្នកពី របៀបយើងខ្ញុំដោះស្រាយបញ្ហារបស់អ្នក។
ប្រសិនបើអ្នកចង់ឱ្យយើងធ្វើការសម្រេចចិត្តយ៉ាងឆាប់រហ័សពីព្រោះពេលវេលាដែលត្រូវការ
ដើម្បីដោះស្រាយពាក្យបណ្តឹងរបស់អ្នកនឹងធ្វើឱ្យជីវិត
សុខភាពឬសមត្ថភាពរបស់អ្នកស្ថិតក្នុងសភាពគ្រោះថ្នាក់ អ្នកអាចស្នើរសុំការពិនិត្យឆាប់រហ័សបាន។
ដើម្បីស្នើរសុំឱ្យមានការត្រួតពិនិត្យឆាប់រហ័ស សូមហៅទូរស័ព្ទទៅលេខ 888-703-6999 (TTY 800-735-2929)។ យើងខ្ញុំនឹងធ្វើការសម្រេចចិត្ត ក្នុងរង្វង់ពេល 72 ម៉ោងបន្ទាប់ពីបានទទួល
ពាក្យបណ្តឹងរបស់អ្នក។

បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ខុសពីបណ្តឹង។ បណ្តឹងឧទ្ធរណ៍គឺជាសំណើសុំឱ្យ LIBERTY ត្រួតពិនិត្យ សើរើនិងកែប្រែសេចក្តីសម្រេចចិត្តដែលយើងខ្ញុំបានធ្វើអំពីការធានារ៉ាប់រងសម្រាប់ សេវាកម្មដែលត្រូវបានស្នើសុំ។ ប្រសិនបើយើងខ្ញុំផ្ញើជូនអ្នកនូវសេចក្តីជូនដំណឹងអំពីការ កំណត់អត្តប្រយោជន៍ដែលមានភាពមិនអំណោយផល (NABD) ហើយអ្នកមិនយល់ស្រប នឹងសេចក្តីសម្រេចនេះ អ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បានឬក៏ PCD របស់អ្នកអាចដាក់ ពាក្យបណ្តឹងឧទ្ធរណ៍ឱ្យអ្នកបាន។

អ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍តាមទូរស័ព្ទឬតាមសារអេឡិចត្រូនិចបាន។ អ្នកត្រូវ ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល 60 ថ្ងៃប្រតិទិនចាប់ពីកាល បរិច្ឆេទនៅលើសេចក្តីជូនដំណឹងដែលអ្នកទទួលបាន។

- ដើម្បីដាក់ពាក្យបណ្តឹងឧទ្ធរណ៍តាមទូរស័ព្ទ សូមហៅទូរស័ព្ទទៅលេខ 888-703-6999 (TTY 800-735-2929)។ សូមផ្តល់ឈ្មោះរបស់អ្នក លេខសម្គាល់សមាជិកគម្រោងសុខភាពរបស់អ្នក និង សេវាកម្មដែលអ្នកកំពុងប្តឹងជំទាស់។
- ដើម្បីដាក់ពាក្យបណ្តឹងឧទ្ធរណ៍តាមទូរស័ព្ទ សូមហៅទូរស័ព្ទទៅលេខ 888-703-6999 (TTY 800-735-2929)។ ស្នើរសុំឱ្យផ្ញើសំណុំបែបបទមួយច្បាប់ទៅអ្នក។ នៅពេលដែលអ្នក ទទួលបានទម្រង់ពាក្យបណ្តឹងរួចហើយ សូមបំពេញវា។ ត្រូវប្រាកដថា អ្នកបាន បញ្ចូលឈ្មោះ លេខសម្គាល់សមាជិកគម្រោងសុខភាពធ្មេញរបស់អ្នក និង សេវាកម្មដែលអ្នកកំពុងប្តឹងឧទ្ធរណ៍។

សូមផ្ញើទម្រង់បែបបទនេះតាមប្រៃសណីយ៍ទៅកាន់៖

LIBERTY Dental Plan
Quality Management Department
340 Commerce, Suite 100
Irvine, CA 92602
Fax: (949) 270-0109

ប្រសិនបើសេចក្តីជូនដំណឹងដែលយើងខ្ញុំបានផ្ញើជូនអ្នកប្រាប់អ្នកថា សេវាកម្មនឹង ឈប់លែងមាន អ្នកអាចបន្តទទួលបានសេវាកម្មនានាអំឡុងពេលនៃបណ្តឹងឧទ្ធរណ៍របស់អ្នក។ ដើម្បីធ្វើដូចនេះ អ្នកឬ PCD របស់អ្នកត្រូវស្នើសុំបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល 10 ថ្ងៃគិតពីកាលបរិច្ឆេទដែលសេចក្តីជូនដំណឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ជូនអ្នក។ អ្នកគួរ តែប្រាប់យើងខ្ញុំថា អ្នកចង់បន្តទទួលបានសេវាកម្មនានា។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍របស់អ្នក យើងខ្ញុំអាចជួយអ្នក បាន។ យើងខ្ញុំអាចផ្តល់ជូនអ្នកនូវសេវាកម្មភាសាដោយឥតគិតថ្លៃ។ សូមទូរស័ព្ទទៅ 888-703-6999 (TTY 800-735-2929) ។

ក្នុងរយៈពេល 5 ថ្ងៃបន្ទាប់ពីទទួលបានពាក្យបណ្តឹងឧទ្ធរណ៍ យើង នឹងផ្ញើលិខិតមួយច្បាប់ឱ្យអ្នកដឹងថាយើងបានទទួលវា។ ក្នុងរយៈពេល 30 ថ្ងៃ យើងខ្ញុំនឹងប្រាប់អ្នកនូវសេចក្តីសម្រេចរបស់យើងខ្ញុំលើបណ្តឹងឧទ្ធរណ៍នោះ។

ប្រសិនបើអ្នកឬវេជ្ជបណ្ឌិតរបស់អ្នក ចង់ឱ្យយើងធ្វើការសម្រេចចិត្តយ៉ាងឆាប់រហ័ស ពីព្រោះពេលវេលាដែលត្រូវការដើម្បីដោះស្រាយពាក្យបណ្តឹងឧទ្ធរណ៍របស់អ្នកនឹងធ្វើឱ្យជីវិត សុខភាពឬសមត្ថភាពរបស់អ្នកស្ថិតក្នុងសភាពគ្រោះថ្នាក់ អ្នកអាចស្នើសុំការពិនិត្យលឿន (ឆាប់រហ័ស) បាន។ ដើម្បីស្នើរសុំឱ្យមានការត្រួតពិនិត្យឆាប់រហ័ស សូមហៅទូរស័ព្ទទៅលេខ 888-703-6999 (TTY 800-735-2929)។ យើងខ្ញុំនឹងធ្វើសេចក្តីសម្រេចចិត្ត ក្នុងរយៈពេល 72 ម៉ោង បន្ទាប់ពីទទួលបានពាក្យបណ្តឹងឧទ្ធរណ៍របស់អ្នក។

សវនាការថ្នាក់រដ្ឋ

សវនាការថ្នាក់រដ្ឋគឺជាជំនួបជាមួយមនុស្សមកពីក្រសួងសេវាកម្មសង្គមនៃរដ្ឋCalifornia (DSS)។ ចៅក្រមម្នាក់នឹងជួយដោះស្រាយបញ្ហារបស់អ្នក។ អ្នកអាចស្នើសុំសវនាការថ្នាក់រដ្ឋតែ **បន្ទាប់ពី**អ្នកបានបញ្ចប់ដំណើរការបណ្តឹងឧទ្ធរណ៍នៅក្នុង LIBERTY ហើយអ្នកនៅតែមិនរីករាយនឹងសេចក្តីសម្រេចចិត្ត ឬប្រសិនបើអ្នកមិនទាន់បានទទួលសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អ្នកបន្ទាប់ពីបានរយៈពេល 30 ថ្ងៃតែប៉ុណ្ណោះ។

អ្នកអាចស្នើសុំសវនាការថ្នាក់រដ្ឋតាមទូរស័ព្ទឬតាមប្រៃសណីយ៍។ អ្នកត្រូវស្នើសុំសវនាការថ្នាក់រដ្ឋ ក្នុងរយៈពេល 120 ថ្ងៃប្រតិទិន គិតចាប់ពីកាលបរិច្ឆេទ នៅលើសេចក្តីជូនដំណឹងដែលប្រាប់អ្នកនូវសេចក្តីសម្រេចចិត្តអំពីបណ្តឹងឧទ្ធរណ៍។ PCD របស់អ្នកអាចស្នើសុំសវនាការថ្នាក់រដ្ឋជូនអ្នកបាន ប្រសិនបើគាត់ទទួលបាន សេចក្តីឯកភាពយល់ព្រមពី DSS។ សូមហៅទូរស័ព្ទមក DSS ដើម្បីស្នើសុំឱ្យ រដ្ឋផ្តល់សេចក្តីឯកភាពសម្រាប់ PCD របស់អ្នកដើម្បីស្នើសុំសវនាការថ្នាក់រដ្ឋ។

ប្រសិនបើសេចក្តីជូនដំណឹងដែលយើងខ្ញុំបានផ្ញើជូនអ្នកប្រាប់អ្នកថា សេវាកម្មនឹង ឈប់លែងមាន អ្នកអាចបន្តទទួលបានសេវាកម្មនានាអំឡុងពេលសវនាការថ្នាក់រដ្ឋរបស់អ្នក។ ដើម្បីធ្វើដូចនេះ អ្នកឬ PCD របស់អ្នកត្រូវស្នើសុំបណ្តឹងសវនាការថ្នាក់រដ្ឋក្នុងកំឡុងរយៈពេល 10 ថ្ងៃគិតពីកាលបរិច្ឆេទដែលសេចក្តីជូនដំណឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ជូនអ្នក។ អ្នកគួរ តែប្រាប់យើងខ្ញុំថា អ្នកចង់បន្តទទួលបានសេវាកម្មនានា។

ដើម្បីស្នើសុំសវនាការថ្នាក់រដ្ឋតាមទូរស័ព្ទ សូមហៅទូរស័ព្ទទៅអង្គភាពឆ្លើយតបសាធារណៈនៃ ក្រសួងសេវាកម្មសង្គមរដ្ឋ California (DSS) តាមរយៈលេខទូរស័ព្ទ **1-800-952-5253**។ **(TTD 1-800-952-8349)**។

ដើម្បីស្នើសុំសវនាការថ្នាក់រដ្ឋតាមប្រៃសណីយ៍ សូមបំពេញទម្រង់បែបបទដែលត្រូវបាន ផ្តល់ជូនអ្នកជាមួយនឹងសេចក្តីជូនដំណឹងអំពីដំណោះស្រាយបណ្តឹងឧទ្ធរណ៍របស់អ្នក។ សូមផ្ញើវាទៅកាន់៖

California Department of Social Services
State Hearings Division
P.O. Box 944243, MS 09-17-37
Sacramento, CA 94244-2430

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការស្នើសុំសវនាការថ្នាក់រដ្ឋ យើងខ្ញុំអាចជួយអ្នកបាន។ យើងខ្ញុំអាចផ្តល់ជូនអ្នកនូវសេវាកម្មភាសាដោយឥតគិតថ្លៃ។ សូមទូរស័ព្ទទៅ 888-703-6999 (TTY 800-735-2929) ។

នៅសវនាការ អ្នកនឹងផ្តល់នូវចំណែកខាងអ្នក។ យើងខ្ញុំនឹងផ្តល់ជូននូវចំណែកខាងយើងខ្ញុំ។ វានឹងស៊ីពេលវេលារហូតដល់ 90 ថ្ងៃសម្រាប់ចៅក្រមក្នុងការសម្រេចសំណុំរឿងរបស់អ្នក។

ប្រសិនបើអ្នកចង់ឱ្យយើងខ្ញុំធ្វើសេចក្តីសម្រេចឆាប់រហ័ស ដោយសារតែរយៈពេលដែលត្រូវប្រើដើម្បីឱ្យមានសវនាការថ្នាក់រដ្ឋអាចធ្វើអោយជីវិត សុខភាព ឬសមត្ថភាពក្នុងការបំពេញមុខងាររាងកាយបានយ៉ាងពេញលេញរបស់អ្នកនៅក្នុងគ្រោះថ្នាក់ អ្នកឬ PCD របស់អ្នកអាចសរសេរលិខិតទៅក្រសួង DSS បាន។
អ្នកអាចស្នើសុំសវនាការថ្នាក់រដ្ឋរហ័សបាន។ ក្រសួង DSS ត្រូវធ្វើសេចក្តីសម្រេចមិនឱ្យលើសពី 3 ថ្ងៃធ្វើការទេ បន្ទាប់ពីបានទទួលសំណើរបស់អ្នកហើយ។

ប្រសិនបើអ្នកមានសវនាការថ្នាក់រដ្ឋរួចហើយ អ្នក **មិនអាច** ស្នើរសុំ IMR បានទេ។ ប៉ុន្តែ ប្រសិនបើអ្នកស្នើសុំ IMR មុន ហើយមិនពេញចិត្តនឹងលទ្ធផលទេ អ្នកនៅតែអាចស្នើសុំសវនាការថ្នាក់ជាតិបាន។

ការបោកបន្លំ ខ្ជះខ្ជាយនិងរំលោភបំពាន

ប្រសិនបើអ្នកសង្ស័យថា អ្នកផ្តល់សេវាកម្ម ឬបុគ្គលដែលទទួលបានកម្មវិធី Medi-Cal បានប្រព្រឹត្តិអំពើបោកបន្លំ ខ្ជះខ្ជាយ ឬរំលោភបំពាន វាជាសិទ្ធិនិងទំនួលខុសត្រូវរបស់អ្នកក្នុងការរាយការណ៍អំពីចំណុចនេះ

ការបោកបន្លំ ខ្ជះខ្ជាយ និងរំលោភបំពានរបស់អ្នកផ្តល់សេវាកម្មរួមមាន៖

- កែប្រែបាយការណ៍ទន្តសាស្ត្រ
- ចេញវេជ្ជបញ្ជាឱសថច្រើនជាងដែលចាំបាច់តាមវេជ្ជសាស្ត្រ
- ផ្តល់សេវាកម្មទន្តសាស្ត្រច្រើនជាងដែលចាំបាច់តាមវេជ្ជសាស្ត្រ
- ចេញវិក័យប័ត្រសម្រាប់សេវាកម្មដែលមិនបានផ្តល់
- ចេញវិក័យប័ត្រសម្រាប់សេវាកម្មព្យាបាលនៅពេលដែលអ្នកប្រកបដោយវិជ្ជាជីវៈមិនបានផ្តល់សេវាកម្មនោះទេ។

ការបោកបន្លំ ខ្ជះខ្ជាយ និងរំលោភបំពានដោយអ្នកដែលទទួលបានអត្ថប្រយោជន៍រួមមាន៖

- ឱ្យខ្ចី លក់ ឬឱ្យប័ណ្ណសម្គាល់សមាជិកគម្រោងធានារ៉ាប់រងទន្តសាស្ត្រឬប័ណ្ណសម្គាល់សមាជិកអត្ថប្រយោជន៍កម្មវិធី Medi-Cal (BIC) ទៅឱ្យនរណាម្នាក់ផ្សេងទៀត
- ទទួលបានការព្យាបាលឬឱសថស្រដៀងគ្នាឬដូចគ្នា ពីអ្នកផ្តល់សេវាកម្មច្រើនជាងម្នាក់
- ទៅកាន់បន្ទប់សង្គ្រោះបន្ទាន់ នៅពេលដែលវាមិនមែនជាករណីសង្គ្រោះបន្ទាន់
- ប្រើប្រាស់លេខបេឡាសន្តិសុខសង្គមឬលេខសម្គាល់សមាជិកគម្រោងធានារ៉ាប់រងទន្តសាស្ត្ររបស់នរណាម្នាក់ផ្សេងទៀត

ដើម្បីរាយការណ៍អំពីករណីបោកបន្លំ ការខ្ជះខ្ជាយ ឬការរំលោភបំពាន សូមសរសេរឈ្មោះ អាស័យដ្ឋាន និងលេខអត្តសញ្ញាណនៃជនដែលប្រព្រឹត្តការបោកបន្លំ ការខ្ជះខ្ជាយឬការរំលោភបំពាននោះ។ សូមផ្តល់ព័ត៌មានឱ្យបានច្រើនតាមដែលអ្នកអាចដឹងអំពីបុគ្គលនោះ ដូចជា លេខទូរស័ព្ទ ឬឯកទេស ប្រសិនបើជននោះជាអ្នកផ្តល់សេវាកម្ម។ សូមផ្តល់កាលបរិច្ឆេទ នៃហេតុការណ៍ដែលបានកើតឡើង និងសេចក្តីសង្ខេបនូវអ្វីកើតឡើងពិតប្រាកដ។

សូមផ្ញើសេចក្តីរាយការណ៍របស់អ្នកទៅកាន់៖

LIBERTY Dental Plan
Special Investigations Unit
340 Commerce, Suite 100
Irvine, CA 92602

ឬទូរស័ព្ទទៅលេខទាន់ហេតុការណ៍សម្រាប់ការបោកបន្លំ ការខ្ជះខ្ជាយ ឬការរំលោភបំពាន
របស់យើងខ្ញុំតាមរយៈលេខ 1-888-704-9833។

7. លេខទូរស័ព្ទនិងពាក្ស សំខាន់ៗដែលត្រូវដឹង

លេខទូរស័ព្ទសំខាន់ៗ

- សេវាកម្មសមាជិក LIBERTY 888-703-6999 (TTY 800-735-2929)
- អ្នកទទួលអត្ថប្រយោជន៍នៃ Denti-Cal លេខ 800-322-6384 (TTY 800-735-2922)
- មជ្ឈមណ្ឌលជំនួយក្រសួង DMHC៖ 888-466-2219
- Health Care Options – Medi-Cal Managed Care 800-430-4263
- Health Consumer Alliance 888-804-3536
- ផ្នែកសិទ្ធិទទួលបានកម្មវិធី Medi-Cal 916-552-9200
- ផ្នែកសវនាការយុត្តិធម៌នៃកម្មវិធី Medi-Cal 800-952-5253 (TTY 800-952-8349)
- Medi-Cal Managed Care 916-449-2000
- Medi-Cal Ombudsman 888-452-8609

ពាក្យដែលត្រូវដឹង

បណ្តឹងឧទ្ធរណ៍៖ សំណើសុំជាផ្លូវការសុំឱ្យ LIBERTY ធ្វើការពិនិត្យឡើងវិញចំពោះសេវាកម្មដែលត្រូវបានបដិសេធ។ បណ្តឹងឧទ្ធរណ៍របស់អ្នកអាចដាក់ដោយទន្តបណ្ឌិតរបស់អ្នក។

អាចអនុវត្តន៍បាន៖ អនុវត្តន៍ចំពោះឬសំដៅទៅលើការមានប្រសិទ្ធភាពលើអ្នកណាម្នាក់ ឬអ្វីមួយ។

ការអនុញ្ញាត៖ សូមមើលផ្នែកការអនុញ្ញាតិជាមុន។

វិក័យប័ត្រថ្លៃសេវា៖ ការចេញវិក័យប័ត្រគិតថ្លៃពីអ្នកជំងឺសម្រាប់ចំនួនខុសគ្នារវាងកម្រៃគិតថ្លៃពិតប្រាកដរបស់ទន្តបណ្ឌិតនិងចំនួនដែលត្រូវបានទូទាត់បង់ថ្លៃដោយគម្រោង LIBERTY។ លើកលែងតែចំពោះតម្លៃសហចំណាយនិងការចូលរួមចំណែកបង់ថ្លៃចំណាយ ការចេញវិក័យប័ត្រគិតថ្លៃទៅលើសមតុល្យមិនត្រូវបានអនុញ្ញាតឡើយសម្រាប់ សេវាកម្មដែលត្រូវបានធានារ៉ាប់រង។

អ្នកទទួលផល៖ បុគ្គលដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍ក្នុងកម្មវិធី Medi-Cal។

ប័ណ្ណសម្គាល់អ្នកទទួលផល (BIC)៖ ប័ណ្ណសម្គាល់ខ្លួននេះត្រូវបានក្រសួងសេវាកម្មថែទាំសុខភាពផ្តល់ដល់អ្នកទទួលផល។ BIC រួមមានលេខរបស់អ្នកទទួលផលនិងព័ត៌មានសំខាន់ៗផ្សេងៗទៀត

ទូរស័ព្ទទៅផ្នែកសេវាកម្មសមាជិកតាមលេខ 888-703-6999 (TTY 800-735-2929)។ យើងនៅទីនេះ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រពីម៉ោង 8:00 ព្រឹកដល់ម៉ោង 5:00 ល្ងាច ។ ការហៅមកលេខនេះគឺឥតគិតថ្លៃ។ សូមចូលមើលគេហទំព័ររបស់យើង www.libertydentalplan.com។

អត្ថប្រយោជន៍៖ សេវាសុខភាពធ្មេញដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលត្រូវបានផ្តល់ដោយទន្ទ្រានិងLIBERTY ដែលមានតាមរយៈកម្មវិធី Medi-Cal Dental។

California Children Services (CCS) Program៖
កម្មវិធីសុខភាពសាធារណៈដែលផ្តល់សេវាកម្មធ្វើរោគវិនិច្ឆ័យ និងព្យាបាល ដល់កុមារដែលមានសិទ្ធិទទួលបានអាយុក្រោម 21 ឆ្នាំ ដែលមានសភាពជំងឺ ស្របតាមលក្ខខ័ណ្ឌរបស់ CCS ដូចដែលបានកំណត់និយមន័យដោយបទបញ្ញត្តិរដ្ឋ។

ដង្ហូរស៊ីធ្មេញ៖ វាក្យស័ព្ទមួយទៀតសម្រាប់ធ្មេញពុកឬប្រហោងធ្មេញ។

Child Health and Disability Prevention (CHDP) Program Services៖ សេវាកម្មថែទាំសុខភាពបែបបង្ការជំងឺសម្រាប់អ្នកទទួលផលមានអាយុក្រោម 21 ឆ្នាំ ដែលត្រូវបានផ្តល់ជូនក្រោមច្បាប់និងបទបញ្ញត្តិរដ្ឋ។

ការឆ្លុះពិនិត្យដើម្បីព្យាបាល៖
ការពិនិត្យដោយទន្ទ្រានដើម្បីផ្តល់មតិយោបល់អំពីភាពត្រឹមត្រូវនៃការព្យាបាលដែលត្រូវបានដាក់ស្នើឡើងឬផ្តល់ជូនដោយទន្ទ្រានៃក្រសួង DMC ផ្សេងទៀត។ LIBERTY អាចនឹងទាមទារតម្រូវឱ្យមានការពិនិត្យរកជំងឺបែបគ្លីនិកសាស្ត្រ នៅក្រោមកាលៈទេសៈជាក់លាក់មួយចំនួន។

ពាក្យបណ្តឹង៖ ពាក្យសម្តីមិនពេញចិត្តដែលសំដែងចេញមកដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សររួមបញ្ចូលទាំងវិវាទណាមួយ ការស្នើសុំពិចារណាឡើងវិញ ឬបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយអ្នកឬទន្ទ្រានក្នុងនាមរបស់អ្នក។ ពាក្យបណ្តឹងក៏អាចត្រូវបានធ្វើឡើងដោយអ្នកតំណាងរបស់អ្នកផងដែរ។

ថ្លៃចំណាយរួម៖ផ្នែកតូចមួយនៃថ្លៃឈ្នួលទន្ទ្រានដែលត្រូវបានបង់ថ្លៃទូទាត់ដោយអ្នកទទួលផល។

សេវាដែលត្រូវបានគ្របដណ្តប់៖ សំណុំនៃនីតិវិធីថែទាំធ្មេញដែលជាអត្ថប្រយោជន៍នៃគម្រោង LIBERTY។ LIBERTY នឹងបង់ប្រាក់តែសម្រាប់សេវាកម្មណាដែលមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលត្រូវបានផ្តល់ដោយទន្ទ្រានរបស់គម្រោងជានាវ៉ាប់រង LIBERTY ដែលជាអត្ថប្រយោជន៍នៃកម្មវិធី Medi-Cal Dental តែប៉ុណ្ណោះ។

អ្នកឯកទេសសុខភាពធ្មេញ៖
ទន្ទ្រានដែលផ្តល់ការថែទាំឯកទេសដូចជាឯកទេសទន្ទ្រាសាស្ត្រទាក់ទងនឹងផ្នែកបណ្តូលធ្មេញ ការរះកាត់មាត់ធ្មេញ ទន្ទ្រាសាស្ត្រកុមារ ឯកទេសទន្ទ្រាសាស្ត្ររចនាសម្ព័ន្ធជុំវិញធ្មេញ និងឯកទេសរីរាង្គសិប្បនិម្មិតធ្មេញ (ខ្សែតម្រង់ធ្មេញ)។

ទន្ទ្រានៃ Denti-Cal៖ ទន្ទ្រានៃដែលត្រូវបានឯកភាពយល់ព្រមឱ្យផ្តល់សេវាកម្មដល់អ្នកទទួលផលនៃកម្មវិធី Medi-Cal។

កម្មវិធីពិនិត្យរកជំងឺ ធ្វើរោគវិនិច្ឆ័យនិងព្យាបាលពីដើមទីនិងយូរៗម្តង (EPSDT)៖
កម្មវិធីសហព័ន្ធដែលផ្តល់ការថែទាំសុខភាពសម្រាប់កុមារ តាមរយៈសេវាកម្មពិនិត្យរកជំងឺ ធ្វើរោគវិនិច្ឆ័យ និងព្យាបាលយូរៗម្តងជាទៀងទាត់។
ការថែទាំទន្ទ្រាសាស្ត្រត្រូវបានដាក់បញ្ចូលក្នុងកម្មវិធី EPSDT ។

សិទ្ធិទទួលបាន៖ សំដៅទៅលើការបំពេញបានតាមលក្ខខ័ណ្ឌទាមទារតម្រូវ ដើម្បីទទួលបានអត្ថប្រយោជន៍កម្មវិធី Medi-Cal។

ការថែទាំគ្រាអាសន្ន៖ ការពិនិត្យ និង/ឬវាយតម្លៃផ្នែកទន្ទ្រាសាស្ត្រ ដោយទន្ទ្រានៃគម្រោង LIBERTY ឬទន្ទ្រានៃឯកទេស ដើម្បីកំណត់ថាតើសភាពសង្គ្រោះបន្ទាន់ផ្នែកទន្ទ្រាសាស្ត្រមានដែរឬទេ និងដើម្បីផ្តល់ការថែទាំដើម្បីព្យាបាលរោគសញ្ញាសង្គ្រោះបន្ទាន់ណាមួយនៅក្នុងរង្វង់លទ្ធភាពនៃបរិក្ខាព្យាបាលស្របតាមការថែទាំដែលត្រូវបានទទួលស្គាល់ជាលក្ខណៈវិជ្ជាជីវៈ។

ល័ក្ខខ័ណ្ឌសុខភាពធ្ងៃញបន្ទាន់: សភាពទន្តសាស្ត្រដែលនៅចំពោះមុខអវត្តមាននៃការយកចិត្តទុកដាក់ភ្លាមៗ អាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថានឹងដាក់សុខភាពរបស់បុគ្គលម្នាក់ឱ្យស្ថិតក្នុងភ័យអន្តរាយ បណ្តាលឱ្យមានការឈឺចាប់ឬការថមថយមុខងារសរីរាង្គធ្ងន់ធ្ងរ។

អ្នកឯកទេសខាងបណ្តូលធ្មេញ: ទន្តបណ្ឌិតឯកទេសដែលដាក់កម្រិតវិជ្ជាជីវៈរបស់ខ្លួនត្រឹមតែការព្យាបាលជំងឺនិងរបួសនៃបណ្តូលនិងឬសធ្មេញតែប៉ុណ្ណោះ។

សេវាមិនរាប់បញ្ចូល: សំដៅទៅលើនិតិវិធីទន្តសាស្ត្រឬសេវាកម្មណាមួយដែលមិនមាននៅក្រោមកម្មវិធី Medi-Cal Dental។

បណ្តឹងសារទុក្ខ: សូមមើលពាក្យបណ្តឹង។

អត្តសញ្ញាណ: សំដៅទៅលើអ្វីមួយដែលបញ្ជាក់ច្បាស់ថាមនុស្សម្នាក់ជានរណាគេ ដូចជាប័ណ្ណបើកបរ។

ដែនកំណត់: សំដៅដល់ចំនួនសេវាកម្មដែលត្រូវបានអនុញ្ញាត ប្រភេទសេវាកម្មដែលត្រូវបានអនុញ្ញាត និង/ឬសេវាកម្មដ៏សមស្របផ្នែកទន្តសាស្ត្រដែលសមល្មមនឹងលទ្ធភាពចំណាយបំផុត។

ចាំបាច់ខាងវេជ្ជសាស្ត្រ: សេវាកម្មដែលត្រូវបានធានារ៉ាប់រងដែលចាំបាច់និងសមស្របសម្រាប់ការព្យាបាលនៃធ្មេញ អញ្ចាញ និងរចនាសម្ព័ន្ធទ្រទ្រង់និងដែលត្រូវបាន (a)ផ្តល់ជូនស្របទៅតាមបទដ្ឋានប្រកបវិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ជាលក្ខណៈវិជ្ជាជីវៈ (b) ត្រូវបានកំណត់ដោយទន្តបណ្ឌិតព្យាបាលថាសមស្របជាមួយនឹងសភាពជំងឺទន្តសាស្ត្រ និង (c) ជាប្រភេទ កម្រិតនិងបរិមាណនៃសេវាកម្មសមស្របបំផុតបើពិចារណាទៅដល់ហានិភ័យជាសក្តានុពល អត្ថប្រយោជន៍និងសេវាកម្មដែលត្រូវបានធានារ៉ាប់រងដែលជាជម្រើសផ្សេង។

សេវាកម្មដែលមិនមានការធានា: ទម្រង់ការឬសេវាកម្មទន្តសាស្ត្រដែលមិនមែនជាអត្ថប្រយោជន៍ដែលត្រូវបានធានារ៉ាប់រង។

ទន្តបណ្ឌិតដែលមិនចូលរួម: ទន្តបណ្ឌិតដែលមិនត្រូវបានអនុញ្ញាតផ្តល់សិទ្ធិឱ្យផ្តល់សេវាកម្មទៅដល់អ្នកទទួលផលដែលមានសិទ្ធិសាកសមនៃកម្មវិធី Medi-Cal។

សេចក្តីជូនដំណឹងអំពីការអនុញ្ញាត (NOA): ទម្រង់បែបបទដែលបង្កើតដោយកុំព្យូទ័រដែលត្រូវបានផ្ញើទៅទន្តបណ្ឌិតជាការ ឆ្លើយតបទៅនឹងសំណើសុំការអនុញ្ញាតផ្តល់សិទ្ធិផ្តល់សេវាកម្មរបស់ពួកគេ។ (សូមមើលសំណើរសុំការអនុញ្ញាតផ្តល់សិទ្ធិព្យាបាល)

ធានារ៉ាប់រងសុខភាពផ្សេងទៀត / ការគ្របដណ្តប់សុខភាពផ្សេងទៀត: ការធានារ៉ាប់រងសម្រាប់សេវាកម្មពាក់ព័ន្ធទន្តសាស្ត្រដែលអ្នកអាចនឹងទទួលបាននៅក្រោមគម្រោងធានារ៉ាប់រងទន្តសាស្ត្រឯកជន កម្មវិធីធានារ៉ាប់រងណាមួយ កម្មវិធីថែទាំទន្តសាស្ត្រសហព័ន្ធឬថ្នាក់រដ្ឋដទៃទៀតណាមួយ ឬនៅក្រោមភាពមានសិទ្ធិទទួលបានតាមផ្លូវច្បាប់ឬតាមការចុះកិច្ចសន្យាដទៃទៀត។

រ:កាត់មាត់: ទន្តបណ្ឌិតឯកទេសកម្រិតការប្រកបវិជ្ជាជីវៈរបស់ខ្លួនតែទៅលើការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលដោយរ:កាត់នៃជំងឺ របួស រ៉ូបភាព ភាពខូចនិងសភាពទ្រង់ទ្រាយនៃមាត់ ថ្គាមនិងមុខតែប៉ុណ្ណោះ។

អ្នកធ្ងរស្រាល: ទន្តបណ្ឌិតឯកទេសដែលដាក់កម្រិតការប្រកបវិជ្ជាជីវៈរបស់ខ្លួនត្រឹមតែការបង្ការនិងការព្យាបាលបញ្ហានៅក្នុងរបៀបដែលធ្មេញខាងលើនិងខាងក្រោមស៊ីគ្នាល្មមតែប៉ុណ្ណោះ។

អ្នកផ្តល់សេវាកម្មក្រៅបណ្តាញ: អ្នកផ្តល់សេវាដែលមិនមែនជាផ្នែកមួយនៃបណ្តាញ LIBERTY។

ការថែទាំបណ្តោះអាសន្ន: ការព្យាបាលដែលសម្រាលភាពឈឺចាប់ប៉ុន្តែមិនបានកែខៃបញ្ហាដែលបណ្តាលឱ្យមានភាពឈឺចាប់ឬផ្តល់តែការកែខៃបណ្តោះអាសន្នតែប៉ុណ្ណោះ។

អ្នកផ្តល់សេវាសុខភាពធ្ងៃញដែលចូលរួមក្នុងបណ្តាញ:

អ្នកផ្តល់សេវាដែលបានចុះឈ្មោះនៅក្នុងកម្មវិធីសុខភាពធ្មេញរបស់ Medi-Cal ដែលផ្តល់សេវាសុខភាពធ្មេញដល់សមាជិករបស់គម្រោង។

ទន្តបណ្ឌិតកុមារ៖ ទន្តបណ្ឌិតឯកទេសដែលកម្រិតការប្រកបវិជ្ជាជីវៈរបស់ខ្លួនត្រឹមតែការព្យាបាលកុមារពីពេលកើតរហូតដល់វ័យជំទង់ ដោយផ្តល់នូវការព្យាបាលបឋមនិងគ្រប់ប្រភេទនៃការព្យាបាលថែទាំបង្ការ។

ពោទ្ធធ្មេញខាងរោគអញ្ចាញធ្មេញ៖
ទន្តបណ្ឌិតឯកទេសដែលដាក់កម្រិតការប្រកបវិជ្ជាជីវៈរបស់ខ្លួនត្រឹមតែការព្យាបាលនៃជំងឺអញ្ចាញនិងដាលិកានៅជុំវិញធ្មេញ។

បុព្វលាភ៖ ចំនួនទឹកប្រាក់ដែលមនុស្សម្នាក់ត្រូវបង់ប្រចាំខែសម្រាប់ការធានារ៉ាប់រងធ្មេញ។ សមាជិកគម្រោងមិនចាំបាច់បង់ថ្លៃបុព្វលាភធានារ៉ាប់រងទេ។

ការអនុញ្ញាតិជាមុន៖ សំណើរសុំដោយទន្តបណ្ឌិតនៃគម្រោង LIBERTY ឱ្យឯកភាពយល់ព្រមលើសេវាកម្មមុនពេលពួកវាត្រូវបានធ្វើឡើង។
ទន្តបណ្ឌិតទទួលបានសេចក្តីជូនដំណឹងពីការអនុញ្ញាតផ្តល់សិទ្ធិ (NOA) ពី LIBERTY សម្រាប់សេវាកម្មដែលត្រូវបានឯកភាពយល់ព្រមហើយ។

លេខកូដនីតិវិធី៖ លេខកូតដែលកំណត់អត្តសញ្ញាណសេវាកម្មវេជ្ជសាស្ត្រ ឬទន្តសាស្ត្រជាក់លាក់ទាំងឡាយ។

អ្នកឯកទេសខាងធ្មេញសិប្បនិម្មិត៖
ទន្តបណ្ឌិតឯកទេសដែលដាក់កម្រិតការប្រកបវិជ្ជាជីវៈរបស់ខ្លួនត្រឹមតែការប្តូរដាក់ជំនួសថ្មីនូវធ្មេញដែលបាត់ដោយធ្មេញសិប្បនិម្មិត ធ្មេញស្ពានតំណឬគ្រឿងជំនួសដទៃទៀត។

អ្នកផ្តល់សេវា៖ ទន្តបណ្ឌិតនីមួយៗ អ្នកឯកទេសអនាម័យធ្មេញដែលមានចុះបញ្ជីការនៅក្នុងការប្រកបវិជ្ជាជីវៈជម្រើសផ្សេង (RDHAP) ក្រុមទន្តបណ្ឌិត សាលាទន្តសាស្ត្រ ឬគ្លីនិកទន្តសាស្ត្រដែលត្រូវបានចុះឈ្មោះ នៅក្នុងកម្មវិធីទន្តសាស្ត្រ Medi-Cal ដើម្បីផ្តល់ការថែទាំសុខភាព និង/ឬសេវាកម្មទន្តសាស្ត្រដល់អ្នកទទួលផលនៃកម្មវិធី Medi-Cal។

បញ្ជីរាយនាមនិងអាស័យដ្ឋានទំនាក់ទំនងរបស់អ្នកផ្តល់សេវាកម្ម៖ បញ្ជីអ្នកផ្តល់សេវាទាំងអស់ក្នុងបណ្តាញ LIBERTY ។

ការបញ្ជូនបន្ត៖នៅពេល PCP
របស់អ្នកនិយាយថាអ្នកអាចទទួលការថែទាំពីអ្នកផ្តល់សេវាផ្សេងទៀត។
ការថែទាំនិងសេវាកម្មដែលត្រូវបានធានារ៉ាប់រងមួយចំនួនទាមទារតម្រូវឱ្យមាននូវការបញ្ជូនបន្តនិងការឯកភាពយល់ព្រមជាមុន។

ការតម្រូវ៖ សំដៅទៅលើអ្វីមួយដែលអ្នកត្រូវធ្វើឬច្បាប់ក្រិតក្រមដែលអ្នកត្រូវតែអនុវត្តន៍តាម។

ទំនួលខុសត្រូវ៖ សំដៅទៅលើអ្វីមួយដែលអ្នកគួរតែធ្វើ ឬត្រូវបានរំពឹងថានឹងធ្វើ។

តំបន់សេវា៖ តំបន់ភូមិសាស្ត្រដែល LIBERTY បម្រើ។
នេះរួមបញ្ចូលទាំងខោនធីនានានៃ ទីក្រុង Los Angeles។

ចំណែកនៃការចំណាយ៖ ភាគចំណែកនៃការចំណាយលើសេវាសុខភាពដែលអ្នកទទួលផលត្រូវបង់ថ្លៃទូទាត់ឬសន្យាបង់ថ្លៃទូទាត់មុនពេលការបង់ថ្លៃទូទាត់ណាមួយរបស់កម្មវិធី Medi-Cal អាចត្រូវបានធ្វើឡើងសម្រាប់ខែនោះ។

ហត្ថលេខា៖ សំដៅដល់ឈ្មោះរបស់អ្នកដែលសរសេរជាសំណេរដៃរបស់អ្នក។

សវនាការផ្នាក់រដ្ឋ៖ សវនាការផ្នាក់រដ្ឋគឺជាដំណើរការផ្លូវច្បាប់ដែលអនុញ្ញាតឱ្យអ្នកទទួលផលស្នើរសុំការវាយតម្លៃឡើងវិញ លើសំណើសុំការអនុញ្ញាតផ្តល់សិទ្ធិការព្យាបាលណាមួយដែលត្រូវបានបដិសេធ ឬផ្លាស់ប្តូរ (TAR)។ វាក៏អនុញ្ញាតឱ្យអ្នកទទួលផលឬទន្តបណ្ឌិតស្នើសុំការវាយតម្លៃឡើងវិញលើករណីផ្តល់សំណងផងដែរ។

សំណើរសុំការអនុញ្ញាតព្យាបាល (TAR)៖ សំណើរដែលត្រូវបានដាក់ជូនដោយទន្ទ្រានិក LIBERTY សម្រាប់ការអនុម័តលើសេវាគ្រូពេទ្យមួយចំនួនមុនពេលការព្យាបាលអាចចាប់ផ្តើម។ TAR ត្រូវបានទាមទារតម្រូវឱ្យមានសម្រាប់សេវាកម្មដាក់លាក់មួយចំនួននិងក្រោមកាលៈទេសៈពិសេស។

ទំរង់ទាមទារសំណង/TAR៖ ទម្រង់បែបបទដែលត្រូវបានប្រើប្រាស់ដោយទន្ទ្រានិកនៅពេលស្នើសុំការអនុញ្ញាតផ្តល់សិទ្ធិដើម្បីអនុវត្តន៍សេវាកម្ម ឬដើម្បីទទួលបានការបង់ថ្លៃទូទាត់សម្រាប់សេវាកម្មដែលត្រូវបានបញ្ចប់សព្វគ្រប់ហើយ។